# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនីពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ សួរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* *ទំព័រ*


| | | |
|---|---|---|
| លោក ហេង-យ៉ាន់ | កំពូលស្នេហា (តមក) . . . . . . . . | ២៨១ |
| ឃុនសុន្ទរមេធី ញង-សឿង | ឯកសហស្សរាត្រី ភាគទី១១ (តមក) . . | ២៩៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ព្រះរាជប្រវត្តិ ព្រះបាទសម្ដេចព្រះជ័យជេស្ដា (ព្រះអង្គសួរ) (តមក). . . . . . . . | ៣០៣ |


*ផ្នែកសាសនា*


| | | |
|---|---|---|
| ឃុនសុវត្ថិវេទី យូរ - អ៊ុន | មិច្ឆាទិដ្ឋិកថា (តមកនិងចប់) . . . . . . | ៣១៣ |
| ព្រះគ្រូមហាបទុម មាឃ-ស៊ុន | ឥន្ទវគ្គបរិយាយ (តមក) . . . . . . . . | ៣៣១ |


ឆ្នាំទី ១៨– លេខ ៦ ខែឧសភា ១៩៤៦– ដំឡៃជា: ១ ឆ្នាំ ៣៥ រៀល ។

## កំពូលស្នេហា

# លោកហេង-យ៉ាន់ រៀបរៀង

(តមក)

សោភ័ក្ត្រ- សេចក្ដីនេះក៏ឃើញថាត្រូវប្រាកដ តែមានមិត្តចំពួកខ្លះ ឃើញគូរបស់ខ្លួនបានសេចក្ដីសុខ បែរជាបំផ្លាញសុខរបស់គ្នាចេញ យ៉ាងហ្នឹង ខុសជាមនុស្សបែបណាទៅ? ។

អាចារ្យ- ត្រង់នេះហើយដែលលោកពោលថា "កាលខ្លីកុំធ្វើឲ្យវែង" ការដែលមិត្តប្រព្រឹត្តល្មើសលើយើង ឬមួយក្បត់ចិត្តយើង បើយើងចេះអត់សង្កត់នោះជាការប្រសើរណាស់ នឹងមិនមានរឿងវែងតទៅទៀត សេចក្ដីចងពៀរសោតក៏នឹងនៅត្រឹមហ្នឹង ម៉េចឯងយល់ហើយឬនៅ? ។

សោភ័ក្ត្រនៅស្ងៀមមិនមាត់ តែប្រាប់ក្នុងចិត្តថា គាត់នេះលេងខ្លួនហើយល្អណាស់ អាចារ្យឯងប្រាជ្ញហើយ គំនិតយើងមិនដល់ទេ ក៏ខ្ញុំតែឯងទៅចុះ គ្នាក់ទឹងតែកដើមខ្ទង់ស្លាប់ទៅហើយ ។

លុះដើរដល់តៀមចិនលក់បបរ ក៏នាំគ្នាទាំងពីរនាក់ចូលទៅអង្គុយហុតបបរដោយសប្បាយ នេះពីរនាក់គេរួចមុន ទៅសល់តែសោភ័ក្ត្រម្នាក់ឯង ព្រោះមិនបានជាតិកហុតប៉ុន្មាន ដល់គេងើបទៅតែខំភក់ៗទៅបាន ក្បាកខ្លួនព្រឹកខំបង្ហើយឲ្យអស់ពីចាន នៅផង់ចាំគេក្រឡប់វិលមកវិញ

ប្រាណទីក្រោយមកក៏អញ្ជុញមិនដឹងជាទីដកយ៉ាងណា ព្រោះខ្លួនមិនបានជាប់លុយមកផង ថ្ងៃនោះរាំ "គជ" កមួយសេនគាត់ទើបទឹកចិត្តចូលចិត្តអាចារ្យសន្ទឹក ក្មេងទឹកដល់គុណេ ដល់សេចក្ដីបង្គម និយាយទីងមិនឲ្យកើតលុយ ហើយនិយាយប្រាប់ថា ចាំស្អែកសឹមយកលុយ បិនក៏ព្រមព្រោះសោភ័ក្រ្តជាប់ចិត្តចូលគៀមនោះ ។

លុះអាចារ្យទឹងសុភាចារបុរសវិលមកវិញ ទើបអាចារ្យលួកយកលុយឲ្យបិន តែសោភ័ក្រ្តឃាត់មិនព្រមឲ្យបញ្ចេញព្រោះខ្លួនបញ្ចេញរួចហើយ តែអាចារ្យបេះតែបញ្ចេញឲ្យថ្លៃបងទៅ ដើរដល់ទីស្ងាត់ សោភ័ក្រ្តទាប់ទាញអាវអាចារ្យខ្លាចនិយាយថា "អាចារ្យមិនគួរលក់មុខខ្ញុំបាន ដូច្នេះសោះ" ។

សុភាចារបុរស- "នែ! សោភ័ក្រ្តឯងថាហ្នឹងខុសទេ គិតឲ្យស្រួលទៅចុះ យើងមានគិតលក់មុខឯងពីកាលណា យើងទៅរកទីចងកទេតើ ម្ដេចក៏ប្រកាន់យ៉ាងហ្នឹង" ។

សោភ័ក្រ្ត- "លោកមិនជ្រាបថ្មទេ អាចារ្យចង់តែបំបាក់មុខខ្ញុំព្រោះឃើញខ្ញុំក្រ បើស្ដួចខ្ញុំណាស់យកកាំបិតមកសំឡាប់ខ្ញុំតែម្ដងទៅ" ។

អាចារ្យគីង ដើមទ្រូងក៏ដកខ្លួនថយពីដៃសោភ័ក្រ្តយ៉ាងខ្លាំង សោភ័ក្រ្តស្មានថាអាចារ្យកេរ្ដិ៍ ក៏ប្រឹងស្ទៀតដាល់អាចារ្យចំបង្កាផ្កាទៅក្រោយ អាចារ្យទ្រេតខ្លួនទៅប៉ះលើជញ្ជាំងផ្ទះឮត្រាំង សោភ័ក្រ្តគិតថែមទៀតតែ

អាចារ្យហើសគេបានទំចប់ខ្លួនឲ្យត្រង់ឡើងហើយកបសនវិញនោះត្រឡឹង ជំទាវយ៉ាងជួរ សោភ័ក្រ្តដួលដល់ផែនដី បាត់សេចក្ដីឈឺចាប់ជាច្រើន ហើយដឹងខ្លួនប្រាស់ជាចាញ់ប្រៀបអាចារ្យ តែទំប្រឹងក្រោកឡើងចូលប្រយុទ្ធដោយមានះនិគចុះអាចារ្យពីក្រោមបំរុងឲ្យដួលនៅទីនឹកខ្លួន តែអាចារ្យមុខរងោះនោះ បែរជាស្រង់ដៃសោភ័ក្រ្តទាំងពីរឡើងផុតឡើងលើពោះនៅទទេ សោភ័ក្រ្តនឹកថា ផល់សេចក្ដីមរណៈជាន់នេះហើយក៏ភាវនាជាប់មាត់ឈ្នះខ្លួនហៅឈ្មោះថា "ណុជនេត្រនារី មាសបងអើយ" ។

នៅវេលានោះ រូបភាពជួនហ្វាច័យប្រាស់ក្នុងសតិរបស់សោភ័ក្រ្ត នាងមានទឹកមុខស្ងួតស្រពោនយំខ្សឹកខ្សួល ទុបនោយ៉ាងស្ងួន ពោលពាក្យថា "ឱសោភ័ក្រ្តផងប្អូន ម្ដេចមកចោលប្អូនឲ្យនៅតែឯងដូច្នេះមិនអាសូរដល់ចិត្តណុជនេត្រផងបងទេឬ?" ហើយសោភ័ក្រ្តញញឹមតបទៅវិញ "ប្អូន បងស្លាប់ត្រោះនះបំពាក់គត់ បងស្លាប់ព្រោះប្អូនណា! បងលាហើយ" រូបរូបនិមិត្តក៏អន្តរធានទៅ ត្រចៀករលៀងៗ ក្នុងត្រចៀកថា "ល្មមយើងវិលទៅផ្ទះវិញហើយ" ទើបបើកភ្នែកឡើង ស្រាប់តែឃើញខ្លួនក្រាបលើស្មាអាចារ្យ សោភ័ក្រ្តភ្ញាក់ព្រឺតទើបឡើងយកដៃស្ទាបពោះ ក៏គ្មានជំងឺអ្វីដូចធម្មតា ដូច្នោះឯង នាំឲ្យអាចារ្យទឹងសុភាពបុរសសើចព្រមគ្នា ទើបអាចារ្យលួងលោមថា ឯងស្មានថាខ្ញុំជាមនុស្សឃាតកឬ? ចូរដឹងប្រាស់ថា ខ្ញុំជាអាចារ្យពិតមិនមានចិត្តព្រះញាន់ឲ្យគេបែកបាក់គ្នាទេ

ណ្ហីយបាត់ចិត្តទៅ   តាំពាក្យសុភាសិតដែលខ្ញុំបានអធិប្បាយឲ្យស្តាប់កាលពីមុននោះទុកជាច្បាប់តទៅមុខ" ។

សោកក្រៀមខ្លួនខុស   លុតជង្គង់ចុះសំពះសូមទោសអាចារ្យរូបបានលាត្រកទាំងពីរវិលត្រឡប់ទៅសំណាក់អាត្មាវិញ   ទឹកមិនអស់ចិត្តនឹងខ្លួនបានប្រព្រឹត្តឲ្យគ្រងលើអាចារ្យជាអ្នកមានគុណលើក្បាល   មិនគួរសោះហេតុតែមាតុគ្រាមធ្វើឲ្យវង្វេងនឹងនឹកមុខ   ទឹកបង់ជាកំណុកមន្ទិលឲ្យសមភាពកំហុស   ចុងបន្តស់បានហួសគិតដល់ណាដនេត្រូវក៏ជកជង្ហើមធំ ។

"អនិច្ចាហ្ន៎!   អំណាចមាតុគ្រាមអាចនឹងសង្កត់សង្កិនជីវិតរបស់សត្វលោកឲ្យអន្តរាយចុះ ជាសភាវៈតែងតែមិននឹងបដូចគង្ហារ   កម្រនឹងប្រែទៅនឹងពត់ឲ្យល្អបាន   ជាសត្រូវចំបងផងសត្វលោក   ជាសភាពបដិកូល ពុំគប្បីសេពគប់ មិនថើងដោយហេតុដ៏កំបាំងអ្នកបានជាសត្វលោកកល់រូបគាប់ចិត្តនឹងអស់ធម្មជាតិនេះអីម៉្លេះ   មិនគួរបើកាំងស្រ្គៈភាពជាកំពូលត្រយដរិតសោះ   សមតែទុកជាតុក្កតាសំរាប់តាំងកាលអតែប៉ុណ្ណោះកន្ទ្រពកៈសំទៅហើយ ។

ដែលយើងមិនអាចនឹងសង្ខ្យាបាននោះ   គឺយើងស្មោះត្រង់ដល់ត្រសំឡាញ់របស់យើង   ដូចស្មុនខដែលស្មគដល់ម្ចាស់របស់វាហួតដល់លះបង់ប្រយោជន៍ផ្ទាល់ខ្លួន   អាស្រ័យតែគាប់ចិត្តយើង   កុំនិយាយចុះអំពីទុក្ខវេទនាដែលយើងបានទ្រាមកនោះ   មួយហើយនៅមិនត្រូវចិត្ត

នាងទៀត នាងនៅធ្វើព្រងើយមិនមេត្តាប្រណីដល់ប៉ុនសរសៃសក់ ថែរ
ជាគំនេះគំរើយដំកើងថ្កូឲ្យថ្ងៃជាន់យើងដកប មិនតែប៉ុណ្ណោះមានដល់
ទៅទទួលភារៈអ្នកដទៃទៅវិញ នាំឲ្យយើងម្នាម្នញតែម្នាក់ឯង ឃើញ
ជាមាតុគ្រាមនេះជាអសិរពិសគួរឲ្យខ្លៀសអាង តែបណ្ដាយឲ្យរាំចិតបាន
ហើយ គំសួលពិសនោះទីងផ្សព្វផ្សាយជ្រួតជ្រាបពាសពេញតែគ្រាន់
កាយ មិនងាយទីងកំចាត់ឲ្យឃ្លាតចេញបានឡើយ ។

ឧហ្ន៎ជីវិតមនុស្ស !

## វគ្គទី ៧

## អនិញ្ញយ៉ាយី

ចុះអ័ព្ទមិនទាន់ស្មាងរសាយនៅឡើយនៅមើលឃើញព្រិលៗ មិន
សូវច្បាស់ តែគេឮសូរសន្ធឹកមាត់អ្នកចេញពីផ្ទះឈើមួយ ដោ
ដើងក្រានក្អឹងកេះសន្ធោសន្ធៅ បានក្បាលខ្ទិចគ្នានាំឲ្យដឹងថាអ្នកផ្ទះមាន
រវល់ធ្វើបុណ្យតានដោយពិត គេកំពុងរៀបចំធ្វើបុណ្យឧមុទ្ទៈលាភធាន់ ៗ
ផ្ទះនោះសង់អំពីឈើលាបពណ៌ខៀវមានយ៉ពីរខាងមុខ ទើបនឹងសង់ចំនួន
បីឆ្នាំប៉ុណ្ណោះ ព្រោះគ្រឿងនៅក្រហមស្អាតនៅឡើយ មុខផ្ទះមានសួន
ដើមផ្កាដាំជាជួរមានរបៀបរៀបរយ ជាគេហដ្ឋានជីវិតល្អស្រស់ស្រួលដែល
សោភ័គ្រក្រៃធ្វើឲ្យរកសំបុត្រ ។

ចំនោះ ផុះពោះបន្តិចកន្ទាប មុខស្រស់ញញឹម មានពុកមាត់គាត់ខ្លីៗ ប្រកបដោយចិត្តអធ្យាស្រ័យ តែជាក់ល្អមិនចេះប្រកាន់ទោសអ្នកដទៃ មានតែពឹងពាក់គេកល់គ្នាមិនរើសមុខ ។

ចំពុកមាត់ខ្លីមានកូនស្រីមួយ ទើបនឹងចូលក្នុងអាយុ ១៨ឆ្នាំ ហើយគាត់បានពិនិត្យឃើញកិរិយាគំនិតសោភ័ក្រ្តជាអ្នកត្រឹមត្រូវ ទើបចង់ភ្ជាប់ជាសាច់ញាតិ ឯសព្វថ្ងៃមានកិច្ចរវល់អ្វីៗ តែងហៅសោភ័ក្រ្តមកជួយជានិច្ចមិនដែលខាន ។

មុននោះមួយថ្ងៃ ចំខ្សែល្អសបានឲ្យបម្រើទៅហៅសោភ័ក្រ្តមកប្អូនជាយប់នោះសោភ័ក្រ្តអង្គុយលេងនៅមុខផ្ទះម្នាក់ឯង កំពុងកំរើបនឹងខ្វល់ក្នុងចិត្តពុំសប្បាយ ដល់គេទៅហៅក៏ទីទៃទៀតថា ពេលព្រឹកស្អែកនឹងជួបមុខកូនក្រមុំចំ នឹងបុត្រអ្នកជិតខាងម្នាក់ទៀតដែលគេប្រមូលទុកឲ្យដែរក្មួយឲ្យលំបាកចិត្តមិនដឹងនឹងធ្វើកម្មវិធីបណាន់យកចិត្តនារីណា បែរទៅភាគណោះ ខ្លាចខាងណោះខឹង តែណ្ហើយតាមវាសនាចុះ ។

ដល់ព្រឹកឡើង សោភ័ក្រ្តភ្ញាក់ពីព្រលឹមទៅផ្ទះចំខ្សែល្អសបានជួយគុបតែងរៀបចាត់ការជាដើម ហើយបោសច្រាសសំអាតផ្ទះក្រោលកន្ទេលឲ្យស្រួលបួល ដល់ពេលលោករៀបចាន់ សោភ័ក្រ្តក៏លុតជង្គង់ក៏ចូលទៅជួសបាយដាក់ចានត្រៃ រូបលើតផៃប្រណាម្យនៅវេលានោះតែគ្រាសោភ័ក្រ្តសំឡឹងមើលនារីទាំងពីរនោះ ក៏ភ្ញាក់ខ្លួនដោយលំអរបស់

ម៉ាន់តាំងពីរ ពីបាកចិត្តខឹងរើសរែដែរ សុទ្ធតែកើតទោមតាំងពីនាក់ ណា ព្រលែកភ្នែកដោយពន្លឺត្បូងពេជ្រដេញផ្កាៗនៅទីក្រៃពេកនាង ។

តែលោកស្រីកាត់ចិត្តធ្វើអភិវឌ្ឍនាការ ចំពោះបុត្រីថៃខ្សែល្អសស្រោះ រូបនាងចំណាប់ណាស់ ហើយកិរិយាមារយាទរបស់នាងក៏សុភាពរៀបរយ ល្អ សាច់ក៏ម៉ដ្ឋឡើងណាមបំព្រងគួរពេកនា ស្រស់ជាងណាដដទេត្រនារីជាំ ច្រើន មើលចុះភ្នែកក្រពះស្រឡះដូចពន្លឺព្រះភាព តែមិនយាយកាលណា គ្រប់ភ្នែកក្រោមក៏ឡើងជាផ្កត់ ភ្នែកនោះល្អមសមនឹងដួងភក្ត្រារបស់នាង មិនតូចហួសខ្នាតមិនធំហួសមាត្រ សំដែងប្រាប់ថាជាអ្នកមានបដិភាណ ក្រៀវក្រា មានពោលហាក្រោះក្រាយ កន់ខាងតូចស្តើងល្ហសក្រុទមិនពេង ទៅមុខ មិនតែខមកក្រោយ ដំណើររៀបរយសមរម្យមិនលេះលោះង ។ លោកស្រីស្ទើរតែមិនជឿដល់ភ្នែករបស់ខ្លួន ខកស្មានជាយល់សប្តិ មាន មុខប្រែក្លាយពីទុក្ខសោកហ្មង ថៃរជាញញឹមបំព្រងឡើង ។ អ្នកតាំងគស់ គ្នាឃើញអាការកិរិយាលោកស្រីដូច្នោះ ក៏ញញឹមរៀងកល់ខ្លួនធ្វើឲ្យកំឡោះ ក្រមុំទាំងគូនោះអៀនអន់ដាក់មុខ ។

ដល់ពេលអាហារ លោកស្រីត្រអែងុយជិតនាងតាំងពីរ ហៅសែន អៀនអស់យ៉ាំងហើយ ស្ទើរខ្ទឹងលេបបាយមិនចូល ណាចង់មើលនាង ផង ណាទំបែងកុំឲ្យគេឆ្ងល់ខុសរបៀប ត្រាតែញ័រដៃបន្តិចៗ ។

----

ដល់ចំណាប់រួច បន្ទែមក៏ក្រឡេតមកតាំងនៅមុខ មានសង់ខ្សែរលើប ភ្ញួនជួងឈ្មួយអប់ផ្កាម្ទះផង ត្រាប់ខ្ទរលឿងម្ទិនឆ្នៅជួបផែលកំពីតមាស ខ្ទេហួយផ្ទែមត្រដាក់ ពេយទឹកតកពីលើ ទឹងផ្ទៃលើងទៀត ១ ជាប្រែន សុទ្ធផាបំណាំប្រណីតតាំងអស់ សោភ័ក្ត្រពមមុខណាក់ពេញបុក្គ ។ ទើប មានយាយដកម្នាក់និយាយជន្ទូជន្ទេញឡើងថា :

"ម៉ែបអ្នកបង្គំកូន បន្ទែមហ៊ីងគួរសមទេ?

"បាទលោកយាយ បន្ទែមអស់នេះមានទុជារសណាស់ អ្នកផែល ធ្វើនោះសមជាគ្រប់ល័ក្ខណ៍ហើយ យ៉ាងហ៊ីងបានបំផាមេផ្ទះយ៉ាងឯក ជាអ្នកស្គាល់ឆាទំរបស់ស្ត្រីភាព មិនដូចនារីខ្លះបេះកាសាផទៃសួចស្តើង ធ្វើងមិនចង់ចូលផើងក្រាន គិតតែពីសំការឆាយជាត់មេស្រ្លាបបរបូមាត់ ក្រហមព្រោះទឹកអប់សព្វសព៌ាងកាយ ផើរលេងហ៊ីហាមិនប្រព្រឹត្តតាម ច្បាប់ស្រី ខុសឆ្ងាយពីប្រវេណីបុរាណ ព្រោះនារីអស់នោះយល់ឃើញថា "ការប្រព្រឹត្តបែបនោះសំផែងឲ្យដឹងថា ឆានមានការស្រេចមិបរិបូណ៌មិន ដូចកូនស្រីនៅតែកង្ដះតួបជាជាប់ឃុំ" ។

"ចុះអ្នកបង្គំកូនឯង ជានរណាធ្វើម្ហូបចំណីទាំងនេះលន់ស្មានមើល?

"ដំរាបប្រសាសន៍លោកយាយ, បើជាខ្ញុំបានឃើញទឹងក្លួតខ្លាប អ្វីទឹងមិនដំរាប តែនេះខ្ញុំបាទជួបភ្នាក់ទាំងសងខាង ត្រាន់តែនឹកស្មានមើល...... " ។

ចៅខ្សែល្អស ឆ្លើយផ្តែតទៀតថា: "ដៃប្អូនឯងធ្វើណា ក្មួយ"

សោភ័ក្ត្របែរមុខមើលនាង ប្រែះក្អកក្អា នាងក៏អៀនឱនមុខចុះ សោភ័ក្ត្រគិតក្នុងចិត្តថា ទុចជាយ៉ាងណាក៏មិនចាញ់ប្រៀបណុជនេត្រនារីដែរ ព្រោះណុជនេត្រតែងជួរតែរឿយ ៗ ថានាងមិនសូវប្រសប់ខាងមុខស្ងួតណ្ណាំទេ តែដល់ពេលធ្វើបាយ ច្រើនតែគេចទៅណេះទៅណោះ ឲ្យផុតកុំឲ្យត្រូវក្មេកម្តាយស្តីបន្ទោស ព្រោះម្ហូបមិនឆ្ងាញ់ឬក៏បាយឆៅជ្រាយ ឬខ្លោច" ។

ចៅខ្សែល្អសសំឡឹងឃើញអ្នកទាំងពីរមានទឹកចិត្តស្របគ្នាដូច្នោះ ក៏និយាយឡើងទៀតថា:

"មើលក្មួយ ៗ ឯងមិនទាន់ត្រូវការចង់បានប្រពន្ធកូននៅឡើយទេឬអ្វី? នៅលីវតែឯងមិនគាប់ប្រសើរទេ ព្រោះមិនចេះទុកប្រាក់កាសឲ្យគង់ដោយគ្មានបារម្ភព្រួយនឹងគ្រួសារ ក្មួយមានបើចាប់ចិត្តលើរូបនារីណាដែរឬ? បើពេញចិត្តត្រង់ណា ក្មួយប្រាប់ពូចុះ ចាំពូជួយធ្វើជាអ្នកផ្ញើរ ចៅមហាឲ្យ" ។

"ដំណប់ប្រសាសន៍លោកពូ ខ្ញុំបាទមិនយល់ទាស់ដល់ការកសាងគ្រួសារទេ តែខ្លួនខ្ញុំបាទសព្វថ្ងៃនេះ ទំពាល់ក្រនឹងរកអ្វីចិញ្ចឹមប្រពន្ធពុំបាន ទើបខ្ចាប់សេចក្តីនេះចេញ" ។

“កុំព្រួយអី ការនេះទុកភារៈឲ្យពូចុះ ចាំពូគិតគូរវិលវល់ឲ្យបាន ស្រួល ព្រោះឯងដូចជាកូនជាចៅពូដែរ” ។

សោភ័ក្ត្រដោរសេចក្តីយល់ច្បាស់ ក៏នៅស្ងៀមទ្រង់ស្រពោនមុខបន្តិច រួចគិតក្នុងចិត្តថា “តើខ្ញុំគាប់ចិត្តដូចម្តេចបាន បើណុជនេត្រស្និទ្ធជាប់ក្នុងដួងកមលសោភ័ក្ត្រយ៉ាងស្និទ្ធ ដែលជាម្ចាស់ចិត្តរបស់សោភ័ក្ត្រនៅហើយ ឱណុជនេត្រនារីអើយ! ទុកជានាងបែរចិត្តប្រែគំនិតដូចម្តេច រូបបងនៅតែស្រឡាញ់នាងខ្លាំងលើសដើមយេគុណមុខជាខ្ញុំឥតបានជួបមុខប្អូនទៀតហើយ ឱណុជនេត្របណ្តូលចិត្តអើយ! បងស៊ូមុំដែរនៅតែប្អូនមិនមេត្តាទៀត ថ្ងៃនេះយើងឃ្លាតចាកគ្នាដាច់សង្វែង ឆ្ងាយអើយសែនឆ្ងាយគួរឲ្យស្តាយក្រៃណាខ្ញុំស្តាយ ធ្វើម្តេចបានប្អូនដឹងចិត្តបងអេះ មកគ្រានេះបងគោរពតែព្រមទទួលយកកូនថីជាគូគ្រងហើយ តែអាពាហ៍ពិពាហ៍នេះកើតឡើងដោយប្រាសចាកសេចក្តីស្នេហា ព្រោះបងស្រឡាញ់តែប្អូនមួយប៉ុណ្ណោះ ប្អូនជឿចុះកុំមានសេចក្តីយល់អាក្រក់ពីបងហៅទៀត ព្រោះបងផុតសង្ឃឹមហើយមួយវិញទៀតថីក៏មានគុណនឹងបងជាច្រើន សូមជីវិតបងនឹងសោះសូន្យចាប់ដើមពីពេលនេះទៅ អនិច្ចាអើយ ធ្វើម្តេចនឹងឲ្យណុជនេត្របានដឹងចិត្តបងអេះ?

កាលបើអ្នកទាំងអស់គ្នា បរិភោគអាហារស្រេចបរិបូណ៌ហើយ សោភ័ក្ត្រក៏ជួយលើកចានក្បានយកទៅលាងទុកដាក់ សោភ័ក្ត្រអ្នកក្រាំទំង

ផ្ទុះសាប៊ូ ពួកនារីខាងលាងសំអាតហើយរៀបជាជង់ ៗ លើតុៈ ដល់ពេលរសៀលបានទាំងតែស្ងួតទឹក លោកគ្រូក៏រើយកកន្ទេលទៅជូត ដើម្បីទុករៀបជាកំទុកកន្លង គាប់ចួនពេលនោះគ្មាននរណានៅ ៗ តែពីរនាក់នឹងបុត្រីថៃឡូស អ្នកទាំងពីរអង្គុយទល់មុខគ្នាធ្វើការ ៗ

ពេលនោះស្ងាត់ស្ងួនឈឹងឥតមានអ្នកក្រើក អ្នកផ្ទះគេសក់ឡើងសំពតខ្លួនអស់ លោកគ្រូក៏វង្វេងដល់ក្ដីកសត់របស់ខ្លួនគន់តែខ្លាំងឡើងៗ ផ្ចុំមុខមិនសប្បាយ លែងរវល់ចិត្តស៊ើយលេងជាមួយនឹងកុមារនៅមុខខ្លួន កាលបើនាងឃើញទឹកមុខកំឡោះដូច្នោះ នាងរាប់ចិត្តសួរដោយញញើតឡើងថា

“បងព្រួយពីរឿងអ្វីឬ? ឬមួយគុំស្បូវស្រលខ្លួនអត់ញើញទៅសំពត្តបុះ ទុកបានឲ្យខ្ញុំជូតតែម្នាក់ឯងបានហើយ” ៗ

លុះបានឮសំដីពីរោះបាចចិត្តដែលខ្លួនខានបានស្ដាប់ជាយូរណាស់មកហើយ លោកគ្រូក៏យល់ឃើញថានាងនោះអាចនឹងលួងលោមឲ្យខ្លួនឃ្លាតចាកទុក្ខបាន ទើបសំដែងសេចក្ដីអរគុណចំពោះនាងដោយសំរក់ទឹកភ្នែកពីរបីតក់ តែនាងគាត់មិនយល់ទើបកើតចង្ងល់ក្នុងចិត្តសួរទួនឡើងជាពីរដង ពីរឿងហេតុដែលនាំឲ្យកំឡោះនោះកើតទុក្ខ ៗ ដោយអត់ទ្រាំសំងំទុកក្នុងចិត្តមិនបាន ដោយចង់បញ្ចេញសេចក្ដីកំបាំងនៃចិត្តរបស់ខ្លួនឲ្យគេដឹង លោកគ្រូក៏ថ្លែងទុកប្រាប់នាងថា:

“អ្នក! អ្នកមានចិត្តសង្វេតដល់រូបខ្ញុំជាមនុស្សអនាថាឥតទីពឹង

នោះ ខ្ញុំបាទអរគុណអ្នកលើសលែង ឯជីវិតខ្ញុំនោះគ្មានខ្លឹមសារសោះ

ហើយកាលបើខ្ញុំនឹកដល់អនាគតរបស់ខ្ញុំម្ដងៗ តក់ស្លុតរន្ធត់ចិត្តឥតកែកាយ

ហាក់ដូចជាមានអ្វីមកគំរាមមិនឲ្យនៅសុខ អ្នកធ្លាប់ឃើញហើយមហា

សមុទ្រតើមានសភាពបែបណា ជួនទឹកថ្លា ជួនញាប់ញ័រគគ្រឹកដោយ

ព្យុះព្យាមា កើតរលកធំៗ ប៉ុន្តែ អ្នកបន្តិចបានមើលចុះ នាវាតូចមួយ

ដែលអណ្ដែតកណ្ដាលទឹកល្ហល្ហាច កណ្ដាលខ្យល់គាប ខំប្រឹងប្រយុទ្ធ

នឹងទុក្ខភ័យក្ដុំវិលនឹកឈឺងគេមើលទិសតំបន់ពុំឃើញ សង្ឃឹមតែកើន

គោមផ្ទុះប៉ុណ្ណោះ ភាពនាវាកណ្ដាលសមុទ្រមានខ្យល់ខ្លាំងយ៉ាងណា មិញ

ភាពនៃជីវិតខ្ញុំបាទក៏ដូច្នោះដែរ សព្វថ្ងៃស្ទើរតែពន្លឺគោមផ្ទុះ តែគ្រានេះ

ឲ្យអ្នកអើយ ពន្លឺនោះលេចដល់ភ្នែកខ្ញុំបាទហើយ...” ។

សោភ័ក្រ្តដកដង្ហើមធំ ចំណែកកុមារីស្ដាប់សេចក្ដីសោភ័ក្រ្តពុំបាន

ហានបិត្តអាណិតអាសូរកុមារគ្រាតែស្រក់ទឹកភ្នែក ។ ដល់ធ្វើការងារ

សម្រេចហើយ សោភ័ក្រ្តនិយាយណាអ្នកម្ចាស់ផ្ទះវិលមកស្ថានអាត្មា

វិញ ។

(មានត)

ឯកសារស្រាវជ្រាវ

# ឬមួយពាន់មួយយប់ (ជារឿងអារ៉ាប់)

## ភាគទី ១១

## រឿងនាងសួបឹត

(តមក)

អ្នកកំលោះក៏តាំងផ្តើមនិយាយថា "អ្នកស្រី! តាមសច្ចកិរិយាដែលនាងមើលនឹងស្ត្រីបួនសួនអំបាញ់មិញនេះ អាចហុចសេចក្តីឲ្យខ្ញុំយល់បានថា នាងទទួលស្គាល់នៅពេលអានចំពោះព្រះនៃម្ញាន់ចុំណោះ ៗ នាងនឹងបានត្រូវក្រោមស្លាប់ហេតុផលយ៉ាងសំខាន់ ដែលមានប្រាកដ ព្រោះគេជះបារមីទីនឹងឬទ្ធិបេស្តារបស់ទ្រង់ ក្នុងពេលឥឡូវនេះពុំខាន ។ ខ្ញុំសូមសារភាពប្រាប់នាងថា កន្ទុងនេះគឺជាទីក្រុងរបស់ប្រទេសមួយយ៉ាងស្តុកស្តម្ភ ដែលផលពីដើមមានព្រះរាជាគឺព្រះវរបិតារបស់ខ្ញុំហ្នឹងឯងគ្រប់គ្រងរាជ្យមានអំណាចពេញបន្ទុក ។ ព្រះរាជាអង្គនេះ ព្រមទាំងស្រីស្នំក្រមការ, បណ្តាជនក្នុងក្រុងទីបណ្តាលស្តាប់ជាតាំងអស់ក្នុងព្រះនគរ សុទ្ធតែប្រួលចិត្តខាងវេទមន្តផ្សេងៗ គឺជាអ្នកកាន់លទ្ធិបូជាភ្លើងនឹងកាន់លទ្ធិនោះពេញពោះ ណារឌុង ជាស្តេចជាទេវតារបស់ពួកយក្សដែលជាសត្រូវធំនឹងព្រះជាម្ចាស់យើង ។

ព្រះវរមាតាបិតាស្រឡាញ់ខ្ញុំជាទីបំផុត តាំងពីកុមារតូចមក ខ្ញុំមានស៊ីកិលៀនយ៉ាងល្អ ១ នាក់ ជាតិជាអ្នកកាន់សាសនាមហាម៉ូត, នាងនោះបានបេះចាំក្បួនអាល់គួរង់ស្ដូតបំណាន ហើយបេះសេចក្តីអធិប្បាយពន្យល់យ៉ាងចំណាប់ ។ ស៊ីកិលៀនតែងនិយាយនឹងខ្ញុំរឿយ ៗ ថា "ព្រះអយ្យបុត្រ! ក្នុងលោកនេះមានតែព្រះមួយអង្គទេ សូមទ្រង់ប្រយ័ត្នកុំកាន់ប្រឡៃទៅទទួលស្គាល់ ហើយគោរពមនុស្សឯទៀតៗ ឡើយ" ។ នាងបង្រៀនខ្ញុំឲ្យមើលជាភាសាអារ៉ាប់ ហើយគម្ពីរដែលឲ្យមកខ្ញុំហាត់រៀនមើលនោះ គឺក្បួនអាល់គួរង់ ។ កាលខ្ញុំបានបេះចាំស្ដូតហើយ នាងបានអធិប្បាយពន្យល់ខ្ញុំ អំពីគោលឡាក់ហ៊ានរបស់ក្បួនដ៏សំខាន់នេះថែមទៀត ។ ឯកិច្ចដែលនាងបង្រៀនខ្ញុំនេះ គឺលបលាក់មិនឲ្យព្រះមាតាបិតានិងអ្នកផងដឹងឡើយ, លុះនាងបង្រៀនខ្ញុំឲ្យបានបេះដឹងពិតប្រាកដហើយ ទាំងខ្លួនខ្ញុំក៏មានសេចក្តីជឿជាក់ខាងសាសនាមហាម៉ូតមុតមាំហើយនាងក៏ធ្វើមរណកាលទៅ ។ តាំងពីនាងក្ស័យជន្មទៅ ខ្ញុំក៏នៅតែចាំក្បួនអាល់គួរង់នោះជិតជាប់នៅក្នុងដួងចិត្តរបស់ខ្ញុំ តាមរបៀបដែលនាងបានបង្រៀនខ្ញុំ, បំណែកខាង ណារាវុឌ្ឍ ដែលជាព្រះក្លែងក្លាយហើយនឹងការបូជាភ្លើងនោះខ្ញុំស្អប់ខ្ពើមណាស់ ។

លុះគន្លងទៅបាន ៧ ឆ្នាំ ពីរ-បីខែ ស្រាប់តែឮសូរសំឡេងទ្រហឹងអឹងកង កក្រើកខ្ទរខ្ទារពាសពេញទាំងទីក្រុង ហើយសំឡេងដែលគេគាប

ស្តាប់ជាក់ចាំបាននោះដូចតទៅនេះ "ឱហោអស់បណ្តាជនទាំងឡាយ! ចូរអ្នកទាំងអស់គ្នាបោះបង់លទ្ធិព្រះ ណារាឌុន្ន និងលទ្ធិបូជាភ្លើងចោលចេញទៅ; ចូរនាំគ្នាគោរពបូជាចំពោះព្រះតែមួយអង្គប៉ុណ្ណោះ ដែលទ្រង់តែងមានសេចក្តីមេត្តាករុណា" ។

សូរសំឡេងបែបនេះឮពាសពេញទាំងទីក្រុង អស់កាលចំនួន ៣ ឆ្នាំតទៅមុខទៀត, ទុកជាដូច្នោះ ក៏ឥតមានអ្នកណាមួយប្រែគំនិតត្រឡប់មកកាន់សាសនាមហាម៉ុតឡើយ ។ ដល់ទៅថ្ងៃក្រោយបង្អស់នៃឆ្នាំទី ៣, ប្រហែលជាម៉ោង ៣ ឬម៉ោង ៤ ព្រឹក ពួកបណ្តាជនទូទៅទាំងអស់ក្នុងទីក្រុង ស្រាប់តែប្រែក្លាយទៅជាថ្មក្នុងពេលតែមួយភ្លែតប៉ុណ្ណោះ, អ្នកដែលកំពុងសំដែងអាការបែបណា ក៏នៅជាបែបនោះត្រង់កន្លែងដែលខ្លួននៅ (គឺអង្គុយក៏នៅជាអង្គុយដដែល យ៉ាងនេះជាដើម) ។ ព្រះវរបិតារបស់ខ្ញុំក៏ត្រូវទទួលគ្រោះថ្នាក់ដូចគ្នា គឺទ្រង់ក្លាយទៅជាថ្មខ្មៅដែលគេឃើញត្រង់កន្លែងមួយក្នុងវាំងនេះ ចំណែកព្រះវរមាតាខ្ញុំក៏ធ្លាក់ទៅក្នុងបាបកម្មដូចគ្នាដែរ ។

នៅសល់តែខ្ញុំម្នាក់ឯង ដែលព្រះមិនបានដាក់ទោសផ្តន្ទាទាំងនេះដូច្នោះ; តាំងពីពេលនោះមក ខ្ញុំតែងតែមានសទ្ធាជឿជាក់ខ្លាំងបំផុត ហើយខំប្រឹងគោរពព្រះដោយមុឹងម៉ាត់ឥតសល់ពេលណាឡើយ ។ ឱអ្នកស្រីនោម ណាយ! ខ្ញុំជឿប្រាកដថា ព្រះអង្គបានបញ្ជូននាងមកក្នុងទីនេះដើម្បីឲ្យខ្ញុំ

បានលើកលែងខ្ញុំឲ្យផុតសេចក្តីទុក្ខ ខ្ញុំសូមអរព្រះគុណចំពោះព្រះអង្គឥតមានទីបំផុត ព្រោះទីស្ងាត់ផែនដីនេះបណ្ដាលឲ្យខ្ញុំអផ្សុកពេកណាស់" ។

រឿងរ៉ាវទាំងអស់នេះ និងពាក្យទាំងប៉ុន្មានយ៉ាងខាងក្រោយនេះ ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលជាខ្លាំងណាស់ ទើបខ្ញុំម្ចាស់និយាយថា "ទ្រង់! ពិតដូច្នោះមែន ឥតសង្ស័យឡើយ គឺជាគុណបុណ្យព្រះបានដឹកនាំខ្ញុំឲ្យចូលមកដល់កំពង់ផែរបស់ទ្រង់នេះ ដើម្បីឲ្យបានជួបនឹងទ្រង់ហើយអញ្ជើញឲ្យស្ដេចចេញផុត អំពីទីលំនៅដែលមានគ្រោះថ្នាក់យ៉ាងនេះឯង ។ កាលបើទ្រង់បានទតឃើញសំពៅដែលខ្ញុំជិះធ្វើដំណើរមកនោះ ទ្រង់គង់នឹងជ្រាបថា ខ្ញុំជាអ្នកស្រុកស្ដុកស្ដម្ភមួយនៃក្នុងក្រុងបាគដាទ ហើយខ្ញុំបានទុកទ្រព្យសម្បត្តិឯទៀតៗ ច្រើនក្រាស់ក្រែលគួរសមនៅទីនោះ ។ សូមឲ្យតែទ្រង់ស្ដេចទៅជាមួយនឹងខ្ញុំចុះ ខ្ញុំនឹងហ៊ានធានាថ្វាយទីសំណាក់ជាក់ពួនយ៉ាងស្ងាត់ ឲ្យគង់នៅជាសុខសប្បាយ ដរាបទាល់តែទ្រង់បានស្គាល់ស្ដេចកាលីហ្វ៍មានអំណាចជានាយកលើពពួកបរិសទ្យ ហើយស្ដេចនោះនឹងប្រទានកិត្តិយសបណ្ដាស័ក្តិដ៏ខ្ពង់ខ្ពស់ ឲ្យល្មមសមនឹងបុណ្យរបស់ទ្រង់ ។ ស្ដេចនោះគង់នៅក្នុងក្រុងបាគដាទ ហើយដំណើរដែលយើងទៅដល់ដំបូងនោះ យើងមិនមែនឲ្យដំណឹងឲ្យស្ដេចជ្រាបភ្លាមថា ទ្រង់បានទៅដល់ក្រុងនោះទេ ទាំងមិនបាច់អង្វរគេសូមទីពំនាក់ដើមគោនអ្វីឡើយ គឺប្រសើរលើខ្ញុំទាំងអស់ ។ ទ្រង់មិនគួរគង់នៅឲ្យយូរតទៅទៀត

កូនចៅក្រុង ដែលគ្មានរបស់របរគាំពារទុកបំរុងឲ្យគ្រប់គ្រាន់យ៉ាងនេះទេ; សំពៅរបស់ខ្ញុំនោះខ្ញុំប្រគល់ថ្វាយឲ្យនៅក្រោមបង្គាប់ទ្រង់ ស្រេចតែទ្រង់ ទ្រង់សព្វព្រះទ័យរៀបចំតាក់តែងយ៉ាងណាក៏បាន" ។ ព្រះអង្គម្ចាស់នោះ ក៏ទទួលយល់ព្រមតាម រូបហើយយើងបានធ្វៀតយកវេលាកាលគ្រាដែល សល់នៅ គឺពេលដែលមិនទាន់ភ្លឺនៅឡើយនោះ រៀបចំខ្លួនប្រាណនឹង ប្រដាប់ប្រដាបំរុងនឹងចុះសំពៅ ។

លុះដល់អរុណរះឡើង យើងក៏ចេញអំពីកំពង់ចុះសំពៅទៅឯកំពង់ផែ បានចួបនឹងបងស្រីទាំងពីរនាក់, នាយផ្នែកសំពៅនឹងពួកអ្នកទាំង- ឡាយ ដែលមានសេចក្ដីព្រួយបារម្ភទន្ទឹងមើលផ្លូវ ព្រោះបាត់ខ្ញុំម្ចាស់ អស់មួយថ្ងៃមួយយប់ ។ លុះខ្ញុំម្ចាស់បានបង្ហាញឲ្យព្រះអង្គម្ចាស់ស្គាល់ បងស្រីទាំងពីរនាក់ហើយ ខ្ញុំម្ចាស់ក៏សារសព្វដោះសារប្រាប់អ្នកទាំង នោះ អំពីដំណើរដែលឃាត់ខាំងខ្ញុំម្ចាស់មិនឲ្យត្រឡប់មកសំពៅពីថ្ងៃ ម្សិលមិញ ហើយប្រាប់អំពីការបានចួបនឹងស្ដេចកំឡោះនោះ ហើយ នឹងរឿងរ៉ាវរបស់ទ្រង់ព្រមទាំងហេតុផលនៃសេចក្ដីទុក្ខវេទនារបស់ទីក្រុង ដែលថ្កុំថ្កើងនោះផង ។

ពួកអ្នកសំពៅផ្ទេរអីវ៉ាន់ដែលខ្ញុំដឹកយកពីស្រុកទៅនោះ យក ចេញពីសំពៅមកដាក់លើគោក ហើយផ្ទេរទ្រព្យសម្បត្តិសុទ្ធតែមាន ដំឡៃយ៉ាងល្អ ៗ គ្រប់កង ដូចយ៉ាងគ្រឿងពេជ្រ, គ្រឿងមាសនឹងគ្រឿង

ប្រាក់គ្រប់បែបនោះ យកមកផ្ទុកក្នុងសំពៅវិញអស់ពេលជាយូរថ្ងៃ ។ យើងហោលគ្រឿងសម្រាប់តុបតែងផ្ទះជាច្រើនយ៉ាង ដូចយ៉ាងតុះទូ តាំងកៅអីជាដើម ហើយទិញគ្រឿងមាសប្រាក់ឯទៀត ៗ នោះច្រើនណាស់ ព្រោះសំពៅផ្ទុកដល់កំរិតទៅហើយ គ្មានកន្លែងដាក់យកមកឡើយ ក្រែងតែមានសំពៅជាច្រើនទៀតទើបផ្ទុកដឹករបស់ក្នុងកំពង់នោះ យកមកឯក្រុងបាតដាវៀអស់បាន ។

លុះយើងបានផ្ទុកទ្រព្យសម្បត្តិដែលយើងត្រូវការទាំងអម្បាលម៉ាន នោះក្នុងសំពៅរួចស្រេចហើយ យើងបានយកស្បៀងអាហារនិងទឹកខ្លះដាក់បន្ថែមតាមផ្លូវផង ។ បើចំពោះតែត្រង់ស្បៀងនោះ យើងនៅសល់តែគោកដែលបានដាក់សំពៅយកមកពីក្រុងបាល់សូរ៉ា ដល់ចប់ផុត យើងលើកក្ដោងបើកសំពៅចេញពីទីនោះមណ្ដាយតាមទំនងខ្យល់ , សំពៅលឿនលេយតាមជលាស័យសមដូចបំណង ។ ៙

ស្ដេចកំឡោះ , បងស្រីនឹងខ្ញុំម្ចាស់បេះតែនិយាយលេងសើចដោយរីករាយជាមួយគ្នាពល់ ៗ ថ្ងៃ ប៉ុន្តែមិនដឹងជាកម្រាស់អ្វីហ្ន៎! ការសាមគ្គីរបស់យើងនោះមិនបានយូរប៉ុន្មានឡើយ គឺបងស្រីទាំងពីរនាក់បែរទៅជាប្រែចប្រែចក្ខុស្ដេចកំឡោះហើយនឹងខ្ញុំម្ចាស់ លុះតមកក្នុងថ្ងៃមួយជាខាងក្រោយ បងស្រីសួរខ្ញុំម្ចាស់ដោយមធ្យោបាយកលថា កាលណាយើងទៅដល់ក្រុងបាតបាទហើយ យើងនឹងទុកដាក់ព្រះអង្គម្ចាស់

ជាអ៊ី ៗ ខ្ញុំម្ចាស់ដឹងខ្លួនភ្ញាក់ គឺគេដាក់ប្រស្នាសួរត្រង់ផ្លូវនេះ ដើម្បីបង់ជីវិតខ្ញុំម្ចាស់ឲ្យប្រាសលាស់ពុំណោះឯង ៗ ហេតុនោះខ្ញុំម្ចាស់ធ្វើជានិយាយបំអកបំអន់ដំបូងសើចលេងក្រឡប់ក្រឡុកចុះឡើងដោយពាក្យថា "ខ្ញុំយកព្រះអង្គម្ចាស់នេះទៅធ្វើជាប្ដី" រួចខ្ញុំម្ចាស់ក៏ងាកបែរទៅនិយាយនឹងស្ដេចនោះថា "ម្ចាស់ថ្លៃ! ខ្ញុំសូមអង្វរឲ្យទ្រង់យល់ព្រមក្នុងរឿងនេះ កាលណាយើងទៅដល់ក្រុងបាគដាទហើយខ្ញុំនឹងប្រគល់ខ្លួនប្រាណធ្វើជាទាសីយ៉ាងស្កាពពកសាររបស់ទ្រង់ តាមតែទ្រង់ប្រើប្រាស់ចុះខ្ញុំនឹងទុកទ្រង់ជាចៅហ្វាយនាយដោយដាច់ខាត" ៗ

ព្រះអង្គម្ចាស់ឆ្លើយមកវិញថា "អ្នកស្រី! ខ្ញុំមិនដឹងទេ តាមតែនាងលើកទុកលើកដាក់ចុះ, ប៉ុន្តែចំណែកខ្ញុំវិញ ខ្ញុំសុំប្រាប់នាងដោយប្រាកដប្រជា ចំពោះមុខអ្នកស្រីទាំងពីរនាក់ដែលជាបងរបស់នាងថា លុះដល់ពេលនោះ ខ្ញុំយល់ព្រមទទួលតាមពាក្យអញ្ជើញរបស់នាង ដោយទឹកចិត្តសុចរិតស្មោះត្រង់ពិត ៗ; ខ្ញុំមិនមែនទុកនាងជាទាសីទេ ទោះបីយ៉ាងម៉េចក៏គង់ទុកនាងជាប្រពន្ធឬជាមេផ្ទះផង ហើយខ្ញុំឥតរកកាតយកអំណាចអ្វីទេ ស្រេចតែនឹងនាងចុះ" ៗ លុះបានស្ដាប់ពាក្យនេះហើយ បងស្រីខ្ញុំម្ចាស់ទាំងពីរនាក់ក៏បែរទឹកមុខភ្លាម ហើយខ្ញុំម្ចាស់បានសំគាល់មើលតាំងពីពេលនោះមកឃើញថា នាងទាំងពីរនាក់មានចិត្តមិនស្មោះត្រង់ចំពោះរូបខ្ញុំម្ចាស់ដូចកាលពីដើមទៀយ ព្រោះមោហោរបស់គាត់

កញ្ចប់បាយស៊ីបានចុកមួយលើកពីរលើកម្នាក់ៗ  ទៅហើយ  នៅតែបង់ជ្រៀតជ្រៀតដណ្តើមរបស់ផងគេទៀត )  ។

យើងទៅដល់ឈូងសមុទ្របើរ៉ូក  ហើយចូលសំពៅទៅរកក្រុងបាល់សូក, ដោយមានខ្យល់ជំនោរត្រូវក្តៅតែញបន្ទុក  ខ្ញុំម្ចាស់សង្ឃឹមថាស្អែកនឹងបានដល់ទីក្រុងនោះពុំខាន  ។  ប៉ុន្តែលុះដល់ពេលយប់  វេលាដែលខ្ញុំម្ចាស់កំពុងដេកទទួលព្រះពាយទានដំណេកលក់ស្កប់  បងស្រីតាំងពីរនាក់ឆ្មៀតយកឱកាសនោះនាំគ្នាចាប់ខ្ញុំម្ចាស់ទម្លាក់ចោលក្នុងសមុទ្រ  ទាំងព្រះអង្គម្ចាស់នោះក៏ចាប់បោះចោលទៅក្នុងសមុទ្រដែរ  ។  ខ្ញុំម្ចាស់ជ្រមុជជ្រមាំលិចលង់ឈ្លក់ទឹកនៅនាកណ្តាលផ្ទៃសមុទ្រធំធេង  ណាមួយយប់ងងឹតសូន្យសុង  ស្ទើរតែចាក់ភ្នែកមិនយល់  ប៉ុន្តែដោយសារទឹកដោះម្តាយថ្លៃណាស់  ម្ល៉ោះដោយកំពូលសំណាងយ៉ាងអស្ចារ្យ  សូម្បីងងឹតឈឹងយ៉ាងនោះក៏ខ្ញុំម្ចាស់នៅតែមើលឃើញបាន  គឺសំឡឹងមើលទៅខាងមុខឃើញទៅៗ  ប្រាកដដល់ភ្នែកខ្ញុំម្ចាស់ហាក់ដូចជាដី  ទើបខំប្រឹងហែលបណ្តោយខ្លួនសំដៅទៅត្រង់ទីនោះ  ។  កាលព្យាយាមហែលយ៉ាងនេះយូរណាស់ក៏បានដល់ទីជម្រាលឆ្នេរសមុទ្រ ;  លុះដល់ពេលភ្លឺច្បាស់ឡើង  ខ្ញុំម្ចាស់ទើបស្គាល់កន្លែងនោះពិតប្រាកដថាជាកោះមួយតូចស្ងាត់ជ្រងំឆ្ងាយដាច់សន្លុងនឹងពីក្រុងបាល់សូក  ។  ខ្ញុំម្ចាស់ដោះសំលៀកបំពាក់សំងួតហាលថ្ងៃក្នុងទីនោះមួយសន្ទុះ  រួចហើយដើរសៀវៗតាមទីជម្រាលមាត់សមុទ្រ

ឃ្លាន ឃើញផ្លែឈើគ្រប់បែបទាំងទឹកដ៏ថ្លាស្អាត ក៏មានសេចក្ដីធូរទ្រូងដោយសង្ឃឹមថា ទីនេះអាចនាំការរក្សាជីវិតឲ្យបានរស់នៅតទៅពុំខាន ។

ខ្ញុំម្ចាស់គង្គុយសម្រាកកំឡាំងក្រោមម្លប់ឈើ ១ ដើម ក្រឡេកទៅឃើញពស់ ១ មានស្លាប កងធាត់ធំហើយបណ្ដោយខ្លួនវែងសែល លួចសំដៅមករកខ្ញុំម្ចាស់ធ្វើក្បាលងើងៗ បម្រះប្រឡោតទៅខាងស្ដាំម្ដង ខាងឆ្វេងម្ដង ហើយលៀនអណ្ដាតផ្លែមៗ អាការបែបនេះអាចឲ្យខ្ញុំម្ចាស់យល់សេចក្ដីបានថា មានសេចក្ដីអន្តរាយ ឬ សត្វកំណាចមួយទៀតបៀនរកដោយពិត ទើបខ្ញុំម្ចាស់ក្រោកឈរឡើង ហើយក្រឡេកមើលបញ្ឆាក់ទៅទៀត ក៏បានឃើញពស់ ១ ទៀតធំសម្បើមអស្ចារ្យកំពុងខាំពស់មុននោះត្រង់កន្ទុយ ហើយទំព្រឹងលេបដោយកំឡាំងយ៉ាងក្លាពេក ខ្ញុំម្ចាស់មានសេចក្ដីករុណាអាណិតស្ទើរពន់ពេក ។ កងពេលនោះគួរតែខ្ញុំម្ចាស់ខ្លាចហើយគៀសខ្លួនរត់គេចចេញ ប៉ុន្តែបែរជាមានសេចក្ដីអង់អាចហ៊ានប្រឆុយទៅវិញ ទើបចាប់រើសបានដុំថ្ម ១ ដុំដែលនៅជិតខ្លួន ហើយបោលពេញទំហឹងសំដៅពស់ធំដែលកំពុងលេប ។ ដៃខ្ញុំម្ចាស់ដូចជាត្រង់គួរសមដែរ ដុំថ្មនោះត្រូវចំក្បាលពស់អានោះព្រួសរម៉ក, វាក៏ខ្ជាក់ពស់តូចនោះចោលទៅ ។ ពស់តូចបានរួចខ្លួនហើយក៏ត្រដាងស្លាបហោះទៅ, ខ្ញុំម្ចាស់តាមសំឡឹងមើលយូរណាស់ វាហោះទៅតាមអាកាសខ្ពស់ត្រដូចបែកជាងសត្វចម្លែក, ទាល់តែផុតកន្ទុយភ្នែកទើបខ្ញុំម្ចាស់ទៅ

អង្គុយក្រោមម្លប់ ១ ទៀត ហើយក៏ទទួលព្រះកដទានដំណេកលក់ក្នុងទីនោះទៅ ។

លុះរលឹកឡើង ស្រាប់តែភ្ញាក់ខ្លួនព្រឺត ព្រោះនៅក្បែរខ្លួនខ្ញុំម្ចាស់ឃើញមានស្រីម្នាក់ មុខមាត់ស្រស់បំព្រងមានទាំងដើមផ្កាពីមានសម្បុរផ្សេងៗ គ្នា ។ ខ្ញុំម្ចាស់ក្រោកអង្គុយឡើងភ្លាមហើយបានសួរស្រីនោះថា នាងជាអ្វី? នាងឆ្លើយប្រាប់ថា "ខ្លួនខ្ញុំនេះឯងគឺជាពស់ដែលនាងបានជួយឲ្យរួច អំពីកណ្តាប់ដៃសត្វកំណាចក្នុងពេលមុនបន្តិចនេះ ខ្ញុំបាននឹករលឹកដល់ឧបការគុណដែលនាងបានធ្វើដល់ខ្ញុំ ហើយខ្ញុំត្រូវតបគុណដល់នាងវិញ ។ ខ្ញុំបានដឹងទាំងអស់ អំពីសេចក្តីក្បត់ចិត្តរបស់បងស្រីទាំងពីរនាក់ ហើយដើម្បីសងសឹកជំនួសនាងនោះ គឺកាលដែលខ្ញុំបានរួចអំពីគ្រោះថ្នាក់ដោយសារជំនួយរបស់នាងហើយ ខ្ញុំទៅបបួលអស់ទាំងគូអនដែលជាស្រីទេពអប្សរដូចខ្ញុំដែរ ឲ្យគេទៅជួយជញ្ជូនអីវ៉ាន់ទាំងអស់ក្នុងសំពៅនោះ យកទៅទុកដាក់ក្នុងឃ្លាំងរបស់នាងឯក្រុងបាត់ដំបង រួចហើយយើងបានពន្លិចសំពៅនោះចោលក្នុងសមុទ្រទៅ ។ មេផ្កាទាំងពីរនេះគឺជាបងស្រីរបស់នាងហើយ, ខ្ញុំបានសងសឹកធ្វើឲ្យក្លាយភេទទៅជាយ៉ាងនេះឯង ។ សេចក្តីផ្តន្ទាប៉ុណ្ណេះមិនទាន់ជួននៅឡើយទេ ខ្ញុំត្រូវតែឲ្យនាងធ្វើបាបថែមទៀត តាមចំនួនដែលខ្ញុំនឹងប្រាប់នាង" ។

(មានត)

ព្រះរាជប្រវត្តិ

## ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា (ព្រះអង្គស្ងួន)

(តទៅ)

## ព្រះជ័យជេដ្ឋាស្ដេចថយចេញពីព្រះរាជវាំង ឧត្តុង្គឫជ័យទៅប្រថាប់នៅស្រុកកណ្ដាលប៉ាំតម្លឹង

ទើបសម្ដេចព្រះជ័យជេដ្ឋាត្រាស់បង្គាប់ឲ្យឧញ៉ាតេជោ ចៅហ្វាយស្រុកខែត្របាក់ទឹងឲ្យឧញ៉ាធ្លេសេនា (សំ) ឲ្យកាន់សេនាទាហាន ២០០០ នៅក្នុងព្រះបរមរាជវាំង ដល់វេលាយប់ឲ្យដុតភ្លើងជុំវិញបន្ទាយ ឲ្យវាយស្គរផ្ទុំស្នែងឲ្យលាន់ឮរំពងឡើង ដើម្បីឲ្យគង់ទ័ពយួន-ខ្មែរយល់ថាស្ដេចឲ្យលើកទ័ពទៅលុក រួចឲ្យនាយទ័ពនាយកងនាំសេនាទាហានថែស្ដេចឆ្វេង-ស្ដាំ បង្ការក្រែងយួនលើកទ័ពមកតាម ស្ដេចឲ្យដុតព្រះរាជទ្រព្យព្រះទេពីព្រះម្ចាស់ ដោយដំរីសេះរទេះឲ្យលើកចេញទៅមុន រួចស្ដេចឡើងគង់ព្រះទីនាំងគជេន្ទ្រព្រមដោយសេនានិករ ទៅប្រថាប់នៅស្រុកកណ្ដាលប៉ាំតម្លឹង ។ ទើបត្រាស់ឲ្យធ្វើបន្ទាយនៅកណ្ដាលប៉ាំតម្លឹង១អន្លើ នៅព្រៃភ្នួន១អន្លើសម្រាប់ជាទីប្រជុំពល ទ្រង់ចាត់នាយទ័ពឲ្យទៅប៉ាំមន្ទីរដែលទៅកណ្ដាលស្រុកឲ្យបានដឹងគ្រប់ប្រការ ។

ឯទ័ពយួន លុះយប់បានឃើញភ្លើងភ្លឺស្គរស្គរស្នែងទ្រហឹង ស្មានថាទ័ពខាងលើលើកមកលុកក៏ប្រយ័ត្នរក្សាមិនប្រហែស ដល់ព្រឹកឡើង

ទើបដឹងថា ស្តេចយាងចេញពីក្រុងឧត្តុង្គផុតអស់ទៅហើយ ពុំបាន លើកតាមដោយខ្លាចគល់ឧបាយ ក៏លើកទ័ពទៅជ្រោយបង្គុ · ល្វាឯម វិញ ។

ឧកញ៉ាធម្មតេជោ និងឧកញ៉ាតេជះសេនា ដឹងថាទ័ពយួនថយចុះទៅអស់ ហើយ ក៏លើកទ័ពតាមស្តេចទៅជួបជុំនៅបន្ទាយកណ្តាលព្រែកតម្លីង ។

## ព្រះជ័យជេដ្ឋាទ្រង់ចាត់ហៅពញាភក្តីសង្គ្រាម (ហុក) ឲ្យទៅទទួលព្រះកន្លោងពីក្នុងបំណែរាមទ័ព

លុះទ្រង់ជ្រាបថា សេនាធាបានមកជួបជុំហើយ ទើបទ្រង់ប្រឹក្សា ជឹងសេនាបតីថា អ្នកព្រះបទុមកដាំបានជាក្លៀវក្លាណាស់ ដោយបានព្រះ កន្លោងយើងទៅក្នុងកណ្តាប់ដៃ ខ្ញុំយល់ថា ត្រូវទៅអញ្ជើញសម្តេច ព្រះកន្លោងមកពីក្នុងទ័ព ព្រះបទុមកដាំឲ្យបានសិន សឹមធ្វើសង្គ្រាមតទៅ ទៀតតែមិនដឹងជាឈ្មោះណា អង់អាចក្លាហានទទួលភាសា ទៅអញ្ជើញ មកបាន ។ គ្រានោះ ឧកញ៉ាមន្ត្រីសង្គ្រាម (សួស) ក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំយល់ឃើញតែចៅពញាភក្តីសង្គ្រាម ជាប្អូនទូលព្រះបង្គំ មានថ្វីដៃ មានសតិបញ្ញា ក្លៀវក្លាតបេះឧបាយកលដឹងច្បាស់ដឹងស្រាល ។ ទ្រង់ព្រះសណ្តាប់ទ្រង់មានព្រះអំណរណាស់ ទើបត្រាស់ឲ្យហៅចៅ ពញាភក្តីសង្គ្រាម (ហុក) ចូលគាល់ មានព្រះរាជឧង្ការថា យើងមិន

ឃើញអ្នកឯណា នឹងទទួលអាសាទៅអញ្ជើញព្រះអន្ទាងយើងមកបានទេ បងអ្នកថា ឃើញតែអ្នកឯងមួយ មានសតិបញ្ញាក្លាហានល្មមទៅធ្វើការនេះបាន តើអ្នកទទួលយកអាសាយើងបានឬទេ។

ចៅពញាកក្តីសង្គ្រាម (ហុក) ក៏ទទួលយកអាសាដោយស្ម័គ្រ ទ្រង់ត្រាស់ថា បើអ្នកទៅអញ្ជើញសម្តេចព្រះវររាជមាតាមកថ្វាយបាន ដូចបំណងអញ ។ នឹងព្រះរាជទានស័ក្តិ ១០ ហូពាន់តាមចិត្តស្រឡាញ់ ហើយទ្រង់ប្រគល់ព្រះទ្រមង់ ១ វង់ទៅថ្វាយព្រះវររាជមាតាជាបន្ទាល់ ទ្រង់ព្រះបណ្តាំគ្រប់ប្រការ ។ ចៅពញាកក្តីសង្គ្រាមក្រាបទូលថា បើទូលព្រះបង្គំទៅបាន ៦-៧ ថ្ងៃ សូមឲ្យទ្រង់ចាត់គងទ័ពទៅចាំទទួលតាមរយៈផ្លូវដែលត្រឡប់វិញ ។

## ចៅពញាកក្តីសង្គ្រាម (ហុក)
## ធ្វើពិធីអធិដ្ឋានរូបហែលឆ្លងទៅបន្ទាយជ្រោយចង្វា

ថ្ងៃអាទិត្យ ១១ កើតខែមិគសិរ ឆ្នាំជូតឆស័ក (ព.ស. ២២២៨ ) ចៅពញាកក្តីសង្គ្រាម (ហុក) ក្រាបថ្វាយបង្គំលាចេញមកយកខ្ញុំម្នាក់ ជាជំទិតទុកចិត្តឈ្មោះនាយគោនឹងថែ ១ ឈ្មោះតាស្រត់ជាប់តាមទៅផង ។ លុះដល់ភ្នំពេញចូលសំណាក់នៅវត្តព្រះស្រកាលេញ នៅមាត់ព្រែកតាមផុង ដើរស៊ើបដំណឹងបានដឹងថា សម្តេចព្រះវរក្សត្រី យួនយកទៅឃុំទុកក្នុងគុកនៅទីជ្រោយចង្វា ។ ដល់យប់ស្ងាត់ចៅពញាកក្តី

សង្គ្រាម (ហុក) យកទៀនធូបហើយចូលបោសច្រាសអាសនព្រះវិហារ ហើយអុជទៀនធូបបូជាព្រះស្រេចការលើកថ្វាយបង្គំអធិដ្ឋានថា ខ្ញុំព្រះអង្គនេះ មានកតញ្ញូនឹងព្រះបាទមហាក្សត្រជាអម្ចាស់ ហ៊ានលះបង់ជីវិតមិនគិតស្លាប់ ទទួលរកសាមកអញ្ជើញសម្តេចព្រះមហាក្សត្រី ជាព្រះវររាជ-មាតាអំពីកណ្តាប់ដៃនៃពួកសត្រូវ បើសម្តេចព្រះជ័យជេដ្ឋាជាអម្ចាស់ខ្ញុំស្តេចមានបុណ្យ ស្តេចនឹងបានឡើងសោយរាជ្យក្នុងក្រុងកម្ពុជាធិបតីនេះ សូមកុំឲ្យទ័ពយួនមើលឃើញស្គាល់ខ្ញុំឡើយ ដោយសេចក្តីកតញ្ញូរបស់ខ្ញុំសូមកុំបីមានអន្តរាយអ្វីឡើយ សូមទេវតាជួយទំនុកបំរុងឲ្យខ្ញុំទៅអញ្ជើញសម្តេចព្រះវររាជមាតាបានដោយងាយ រួចទៅពញាកក្តីសង្គ្រាម (ហុក) តាំងវៃសូត្រមន្តផ្លុំសណ្តំបង្ហើរទៅតាមខ្យល់ ឲ្យពួកយួនដេកលក់កុំឲ្យដឹងខ្លួន ហើយនាំនាយគោចុះពីព្រះវិហារដើរកេប្សបាន ១ កំណាត់ម្នាក់ផ្តាំផ្តែកស្រែកថា ឲ្យចាំអញនៅមុខព្រះវិហារនេះចុះការឯងនឹងស្លូកុំឈប់ផ្ទៃនោះសំឡេងជំចាំមាត់បាន ។ ដល់យប់ស្ងាត់ ទៅពញាកក្តីសង្គ្រាម (ហុក) បតសំពត់សៀតក្រវាត់ខ្លួនបញ្ចេញទៅតែខោស្នាប់ភ្លៅ សៀតកាំបិតសៀត នាយគោក៏ធ្វើដូចគ្នា រួចនាំគ្នាចុះទឹកហែលឆ្លងព្រែកទៅជ្រោយចង្វា វេលានោះចួនជាមានភ្លៀងមានខ្យល់ផង ពួកពលក្នុងទ័ពវៃ-យួនចូលជ្រកដេកអស់ ទៅពញាកក្តីសង្គ្រាមនឹងនាយគោក៏ឆ្លងទៅដល់ជ្រោយចង្វា តាំងយើតមេយប្បាយសេះបន្តអាគមសណ្តំផ្លុំបង្ហើរទៀត

រួចដើរកកាយគន់មើលសម្ដេចព្រះតាវក្សត្រ ស្រាប់តែក្រឡេកទៅ ឃើញខ្ទមមួយ នៅកណ្ដាលមានស្ពានជាប់មកដល់ច្រាំង មានខ្ទម ឡោមជុំវិញជាច្រើន ហើយដើរគន់មើលក្នុងខ្ទមឃើញស្ដេចផ្ទំលក់ ស្គាល់ ជាក់ជាសម្ដេចព្រះតាវក្សត្រ ក៏នាំនាយគោឡើងលើខ្ទមថ្វាយបង្គំ ទើប ក្សត្រទ្រង់ចំផ្ទំខ្នើយព្រោះព្រលើព្រះអង្គ ទ្រង់បែរព្រះអង្គឡើងគង់ទតមក ឃើញចៅពញាកក្ដីសង្គ្រាម១ ថ្វាយបង្គំថ្វាយព្រះទ្រមង់ក្រាបទូលតបៗ ស្ដេចមានព្រះបន្ទូលថា បានអ្នកឯងមកអញអរណាស់ ដូចបានឃើញ មុខកូន បើយកតែអញតែម្នាក់ឯងអញមិនទៅទេ ត្រូវយកម៉ែវាទៅផង ទើបអញព្រមទៅ ព្រោះវាកំសត់ណាស់ ៗ ចៅពញាកក្ដីសង្គ្រាមក្រាប ទូលថា សូមកុំព្រួយព្រះកជហឫទ័យ ទើបសម្ដេចព្រះតាវក្សត្រទ្រង់ ផាស់នាងអាំឡើងឲ្យរៀបខ្លួនទីនិប្រមូលព្រះកជទ្រព្យ ៗ ចៅពញាកក្ដី សង្គ្រាមអញ្ជើញសម្ដេចឲ្យគង់លើស្នាខ្នង នាងអាំសារឲ្យគជិះលើស្នា នាយគោ ហើយនាំគ្នាហែលទឹកខ្ទង់កម្រង់តាមសម្ពន្ធ័ថ្ងៃល្អ រួចរបួត ពីចំណោមទំពយួនខ្មៅ ទៅឡើងនៅកំពង់វត្តព្រះស្រគាលេញផិតមាត់ វព្រែកពាមផ្លូវវិញ ឲ្យស្ដេចគង់ឲ្យស្រួលហើយ ទើបចៅពញាកក្ដី សង្គ្រាមទឹកនាយគោ ផ្លាស់សំពត់ជាប្រញាប់ អញ្ជើញសម្ដេចឲ្យគង់ លើស្នាខ្នងដើរកាត់ព្រៃតាំងយប់ នាយគោដើរមុខនាងអាំដើរក្រោយដ្រួស ហួសផ្លូវបែក នាយគោសួរថាផ្លូវនេះទៅខាងណា ចៅពញាកក្ដី

ឲ្យបែកទៅខាងស្ដាំដៃ គំនាំគ្នាដើរទៅតាំងយប់រំលងកន្លែងផ្លូវ ដល់ភ្លឺស្រាង ៗ ដាក់ស្មឹងនៅព្រៃក្នោតទើបដឹងថាដើរខុសផ្លូវ ។ ចៅពញាភក្ដីសង្គ្រាមនឹងនាយគោ កាប់មែកឈើធ្វើជាអង្រឹងស្នែងបងទឹងសំពត់នាំគ្នាសែងសម្ដេចដើរទៅ ៗ រហូតដល់ថ្ងៃរសៀល ទ្រង់អត់ព្រះក្រយាហារ ទ្រង់ព្រះកន្ទ្រើង ដល់ទួលផ្ដើងទ្រង់ប្រើនាយគោឲ្យឡើងបេះផ្លែផ្ដើងឲ្យទ្រង់សោយ ឯចៅពញាភក្ដីសង្គ្រាមក៏ដើរកេសុំអាហារអ្នកស្រុកមកថ្វាយ សោយហើយស្រួបសព្វញ្ញាស្ដេចពីទួលផ្ដើង កម្រង់ទៅអង្គព្រះពាយឈប់ផ្ទុំនៅទីនោះ ។

ចំណែកឯទ័ពយួន-ខ្មែរនៅជ្រោយបន្ទា ដល់ព្រឹកឡើងទើបដឹងថាបាត់សម្ដេចព្រះរាជក្សត្រ ហើយនាំគ្នាទៅទូលសម្ដេចព្រះបទុមរាជា ។ ទ្រង់ចាត់អ្នកទៀងទុន ឲ្យនាំសេនាទាហានយួន-ខ្មែរលើកទៅតាមតែពុំទាន់ សេនាទាហានខ្លះត្រឡប់ទៅទូលវិញ ។

## ព្រះជ័យជេដ្ឋាទ្រង់ចាត់ទ័ព ឲ្យទៅចាំទទួលចៅពញាភក្ដីសង្គ្រាម (ហ៊ុក)

ឯសម្ដេចព្រះជ័យជេដ្ឋាទ្រង់ចាត់ឲ្យលើកទ័ព ទៅចាំទទួលចៅពញា-ភក្ដីសង្គ្រាម កងទ័ពដែលលើកទៅទទួលនោះ កាលដឹងថាយួនលើកទ័ពភាយមកក៏ឈប់ចូលសំងំពួនក្នុងព្រៃចាំស្ដាប់ដំណឹង លុះដឹងថាចៅពញា-

កក្តិសង្គ្រាម អញ្ជើញសម្តេចព្រះធាត្រីមកជុំហើយ ក៏មិនពុន ចេញច្បាំងនឹងទ័ពយួន ចាំជួបនឹងចៅពញាកក្តិសង្គ្រាមសិន ។

ចៅពញាកក្តិសង្គ្រាមលុះដឹងថា ទ័ពយួន-ខ្មែរលើកទ័ពមកជិតណាស់ ក៏នាំសម្តេចព្រះធាត្រីទៅបំពួនក្នុងព្រៃខាងលិចអន្ទព្រះ-ពាយ ។ ឯទ័ពយួន-ខ្មែរតាមទៅពុំទាន់ហើយ ក៏ត្រឡប់ទៅបោះទ័ពនៅក្រពើញវិញ ។ ឯចៅពញាកក្តិសង្គ្រាមដឹងថាយួនលើកទ័ពត្រឡប់ទៅវិញហើយ ក៏អញ្ជើញសម្តេចព្រះធាត្រីចេញពីព្រៃផលពួននោះតទៅទៀត លុះដល់ទីនប់ព្រះឥន្ទ្រទេព ទើបស្តេចឲ្យឈប់នៅទីនោះ ។ ចៅពញាកក្តិសង្គ្រាមក៏ប្រើនាយគោឲ្យទៅជំបចៅពញាកក្តិសង្គ្រាម (សួស) ជាបង ឲ្យនាំសេចក្តីក្រាបបង្គំទូលឲ្យទ្រង់ជ្រាប វេលានោះ ស្តេចព្រះរាជដំណើរមកប្រថាប់នៅព្រៃត្រពាំងគង់ក្នុងខែត្រសំរោងទងស្តាំ ។ កាលទ្រង់ជ្រាបរឿងសព្វគ្រប់ហើយ ទ្រង់មានព្រះអំណរពន់ប្រមាណ ទ្រង់ព្រះរាជបញ្ជាឲ្យបងព្រះទីនាំងគជេន្ទ្រស្រេចស្តេចឡើងគង់ ពួកមន្ត្រីខ្ញុំរាជការសេនាទាហាននាំហែហមជាយសបរិវារ ស្តេចព្រះរាជដំណើរចេញពីព្រៃត្រពាំងគងមកដល់ទីកលលំហាប បានជួបនឹងសម្តេចព្រះធាត្រីជាព្រះវររាជមាតានិងចៅពញាកក្តិសង្គ្រាម (ហុក) ទ្រង់មានព្រះអំណរណាស់ ស្តេចចុះពីព្រះទីនាំងទ្រង់ឱបព្រះបាទាព្រះវររាជមាតាទ្រង់ព្រះកន្សែង សម្តេចព្រះវររាជមាតា

ក៏ទ្រង់ព្រះកន្សែង ពណ៌នាពីស្តេចនៅក្នុងគណ្ដាប់ដែកដសត្រូវសព្វគ្រប់ ៗ សម្តេចព្រះរាជបុត្រទូលថា ទូលព្រះបង្គំជាខ្ញុំពុំហ៊ានលើកគង់ទ័ពទៅវាយបន្ទាយភ្នំពេញ-ជ្រោយចង្វា ដោយខ្លាចក្រែងគេធ្វើទុក្ខព្រះវររាជមាតា ឥឡូវនេះ ទូលបង្គំជាខ្ញុំនឹងឲ្យសេនាទាហានលើកទ័ពទៅវាយបន្ទាយភ្នំពេញ-ជ្រោយចង្វា របស់ព្រះបទុមរាជាឲ្យបែកបាក់ទៅទាល់តែបាន ហើយអញ្ជើញសម្តេចព្រះវររាជមាតាឲ្យឡើងគង់ព្រះទីនាំងគជេន្ទ្រស្តេចព្រះរាជដំណើរទៅបន្ទាយគណ្ដាលក្រាំងតម្ទឹង ។

ស្តេចទ្រង់ប្រឹក្សានឹងនាយទ័ពនាយកងទាំងពួងថា ព្រះបទុមរាជាប្រហែលឲ្យលើកទ័ពតាមមកទៀតពុំខាន ត្រូវយើងលើកសេនាទាហានទៅទទួលច្បាំង បើមានទ័ពលើកមកឲ្យមានសំបុត្រផ្ញើក្រាបទូលជាប្រញាប់ នាហ្មឺនសព្វមុខមន្ត្រីក៏យល់ព្រម ទើបទ្រង់តាំង ១ កញ្ញា ១ ទ័យមេធិកធ (សោម) ឲ្យនាំសេនាទាហានទៅបោះទ័ពនៅចុងចិនក្បែរខាងលិច ។

## ព្រះរាជសង្គ្រាមគ្រាទី ៣

## ទ័ពព្រះជ័យជេដ្ឋាវាយបានបន្ទាយភ្នំពេញ - ជ្រោយចង្វា

ឯសម្តេចព្រះបទុមរាជា កាលទ្រង់ជ្រាបថា ទ័ពខ្មែរ - យួនលើកទៅតាមសម្តេចព្រះចៅរាជ្យត្រីពុំទាន់ ក៏ទ្រង់ខ្វល់ណាស់ ទើបទ្រង់តាំង ១ កញ្ញាស្រីអគ្គរាជ (សួស) ១ កញ្ញាធម្មតេជោស្រី ឲ្យនាំសេនា

ទាហាន ១០,០០០ ចូលទន្លេលើកតាមសម្តេចព្រះចៅក្រុង ២ ផ្លូវ ១ ផ្លូវត្រូវស្រឹងទ័ពទឹកថ្ងៃ ១ ផ្លូវគោកម្រង់ទៅក្រុងកុក្កុដព្ភជ័យ ។

ចំណែកឧកញ៉ាឧទ័យធិរាជ (សោម) ក៏ពាក្រោះប៉ែកព្រមព្រៀងគ្នាថាត្រូវចាត់ប្រើឲ្យទៅក្រាបទូលឲ្យទ្រង់ជ្រាបថាប្រញាប់តាមព្រះរាជបណ្ដាំ ហើយអកម៉ឺនថៃបុនរក្សាត់សេនាទាហាន ៤ នាក់ ឲ្យនាំចុតហ្មាយទៅថ្វាយឲ្យទ្រង់ជ្រាប តាមរឿងដែលសម្តេចព្រះបទុមរាជាលើកទ័ពមកពីរផ្លូវគ្រប់ប្រការ ។

ហើយសម្តេចព្រះជ័យជេដ្ឋា ត្រាស់បង្គាប់ឲ្យចៅពញាភក្តីសង្គ្រាម (ហុច) នាំសេនាទាហាន ១០,០០០ លើកគម្រង់ទៅក្រុងកុក្កុដព្ភជ័យ ទ្រង់ចាត់ឲ្យហ៊ុនតាំនាំសេនាទាហាន ៨០០០ លើកទៅជួបឧកញ៉ាឧទ័យធិរាជនៅខែត្រភ្នំពេញ ទ័ពទាំងពីរកងក៏លើកចេញទៅ ទ័ពស្របបានជួបប្រទះគ្នានៅកលហោង កងខ្មែរសំពេងទ័ពច្រើនបានចាប់ច្បាំងគ្នានៅទីនោះ ។ ចៅពញាភក្តីសង្គ្រាមបញ្ជាកងទ័ពកុំឲ្យជ្រួលជ្រើម រួចចាត់ទ័ពជាបីកង កងកណ្ដាលឲ្យលើកទៅជួបប៉ះនឹងទ័ពមុខ ប៉ែកស្តាំឆ្វេងឲ្យវាយស្ទប់ទាំងសងខាង ទ័ពទាំង ៣ កងលើកសន្ធឹងរុតបាញ់កាំភ្លើងធ្នូសាបួលទៅ ទ័ពខ្មែរ-យួនស្លាប់ជោរជោរ ទ្រាំពុំបានបកជ័យរត់ទៅវិញ ។ ចំណែកហ៊ុនតាំនាំសេនាទាហានទៅដល់រួបរួមនឹងទ័ពឧកញ៉ាឧទ័យធិរាជ ក៏ច្បាំងនឹងទ័ពយួន-ខ្មែរនៅភូមិបែកបាន ឯទ័ពដែល

បកជ័យភេរីខ្ចាត់ខ្ចាយចូលទៅបន្ទាយជ្រោយចង្វា វុះចូលពុំបាននោះទេ.
ពញាកក្តីសង្គ្រាមទីឯកញា ៗ ជ័យធិកជ រួមរួមទ័ពជាមួយគ្នាលើកតាមទៅ
ទាន់គាប់សម្លាប់ពលខ្មែរ - យួនស្លាប់ទីងពាប់ឲ្យបានជាច្រើន រួចបម្រួល
ទាហានទៅក្រយបន្ទាយជ្រោយចង្វាទៀត សេនាទាហានខ្មែរ - យួនពុំ
ហ៊ានចេញច្បាំង ទើបអញ្ជើញសម្តេចព្រះបទុមកជា ចុះគង់ព្រះទីនាំង
នាក់ហោលបន្ទាយជ្រោយចង្វាចូលទៅត្រើយល្វាឯម ស្តេចទៅបោះទ័ព
នៅខែត្រស្រីសឈរ ។ ឯចៅពញាកក្តីសង្គ្រាមទីឯកញា ៗ ជ័យធិកជ
កាលក្រយបានបន្ទាយកំពេញនិងជ្រោយចង្វាហើយ ក៏ចាត់ឲ្យប្រមូល
សេនាទាហាននិងគ្រឿងសស្ត្រាវុធ កៀរគ្រួមកដាក់ត្រើយកំពេញវិញ
ហើយចាត់អកហ៊ឹនហោមបៃបុង័ក្សនិងសេនាទាហាន ៦ នាក់ឲ្យនាំសេចក្តី
ក្រាបបង្គំទូលឲ្យទ្រង់ជ្រាបគ្រប់ប្រការ ទ្រង់មានព្រះអំណរណាស់ ស្តេច
ទ្រង់សរសើរចៅពញាកក្តីសង្គ្រាមទីឯកញា ៗ ជ័យធិកជជើងៗ ហើយ
ទ្រង់ព្រះតម្រាស់ថា ចៅពញាកក្តីសង្គ្រាម (ហុក) ល្មមតាំងឲ្យធ្វើ
ជាសេនាបតីបាន ។

ទើបទ្រង់ត្រាស់ឲ្យអកហ៊ឹនហោមបៃបុង័ក្សនាំរបស់មានជ័យជើងៗ
ទៅព្រះកេជតានៈបង្គំពទាំងពីរ និងនាយទ័ពនាយកងទាំងពួកតាមនៀយ
ហត់ទឹកជការទ្រង់ព្រះបណ្តាំថាឲ្យបោះទ័ពនៅកំពេញរក់ផកជស្រុវឲ្យ
មាំមួនកុំបីធ្វេសប្រហែស ។ (មានត)

# មិច្ឆាទិដ្ឋិកថា

## ឃុនសុវត្ថិវិទី យូរ-អ៊ុន រៀបរៀង

(តមកពីលេខមុន)

៤០— បញ្ញត្តថា ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ជាអត្តភាពមិនមានរោគ ស្លាប់ហើយជាសត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ឃ) ពួកសមណព្រាហ្មណ៍ ៧ ពួក (អ្នកពោលថាដាច់សូន្យ) បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយហេតុ ៧ យ៉ាងគឺ:

៤១— បញ្ញត្តថា ខ្លួនមានរូបប្រកបដោយមហាភូតរូប ៤ កើតមកអំពីមាតាបិតា ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៤២— បញ្ញត្តថា ខ្លួនមានរូបជាទិព្វ ជាកាមាវចរទេវតា (ត្រាច់ទៅក្នុងកាមភព) មានកវឡិង្ការាហារជាចំណី ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៤៣— បញ្ញត្តថា ខ្លួនមានរូបជាទិព្វ កើតដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកថយ ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៨៤— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់អាកាសានញ្ចាយតន-គត ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៨៥— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់វិញ្ញាណញ្ចាយតន-គត ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៨៦— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់អាកិញ្ចញ្ញាយតន-គត ស្លាប់ហើយរមែងដាច់សូន្យ មិនកើតទៀត ។

៨៧— បញ្ញត្តថា ពួកសត្វដែលចូលទៅកាន់នេវសញ្ញានា-សញ្ញាយតនគត ស្លាប់ហើយរមែងដាច់សូន្យមិនកើតទៀត ។

ង) ពួកសមណព្រាហ្មណ៍ ជាទិដ្ឋធម្មនិព្វានវាទ (អ្នកពោលនូវនិព្វានគឺសេចក្តីរលត់ទុក្ខក្នុងបច្ចុប្បន្ន) បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណយ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាង គឺ:

៨៨— បញ្ញត្តថា ខ្លួនដែលឲ្យគេបំរើផ្គត់ផ្គង់ដោយកាមគុណ ៥ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

៨៩— បញ្ញត្តថា ខ្លួនដែលបានស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ ហើយបានដល់បឋមជ្ឈានប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈកើតអំពីសេចក្តីស្ងប់ស្ងាត់ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

២០— បញ្ញត្តថា រូបដែលបានរម្ងាប់វិតក្កៈ វិចារៈ អស់ហើយ បានដល់នូវទុតិយជ្ឈាន ជាធម្មជាតផូរផង់ ប្រាកដក្នុងខ្លួន មានសេចក្តីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តខ្ពស់ឯក ជាឈានមិនមានវិតក្កៈ វិចារៈ មានតែបីតិនិងសុខៈកើតអំពីសមាធិ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

២១— បញ្ញត្តថា រូបដែលប្រកបដោយឧបេក្ខាផង មានស្មារតីផងដឹងខ្លួនផង បានសោយសុខដោយនាមកាយផង ព្រោះអស់ទៅនៃបីតិក៏បានដល់នូវតតិយជ្ឈាន ជាឈានដែលប្រកបដោយឧបេក្ខានិងសុខៈ ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

២២— បញ្ញត្តថា រូបដែលបានលះបង់សុខៈផង លះបង់ទុក្ខផង មានសោមនស្សនិងទោមនស្សអស់ហើយក្នុងកាលមុន ហើយបានដល់នូវចតុត្ថជ្ឈាន ដែលជាឈានមានអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខាវេទនា ទើបឈ្មោះថាជាអត្តភាពបានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ជាអ្នកប្រកបដោយបុព្វន្តកប្បិកទិដ្ឋិ អបរន្តកប្បិកទិដ្ឋិ បុព្វន្តាបរន្តកប្បិកទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញនូវខន្ធជាចំណែកខាងដើម គឺខន្ធក្នុងអតីតកាល និងខន្ធជាចំណែកខាងមុខ គឺខន្ធក្នុងអនាគតកាល ព្រោះខន្ធជាចំណែក

ខាងដើម ទិដ្ឋិជាបំណែកខាងមុខ តែងតែសំដែងដោយហេតុទាំង ៦២ ប្រការនេះឬក៏បណ្ដាហេតុទាំង ៦២ ប្រការនោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ ពួកសមណព្រាហ្មណ៍ទាំងនោះសុទ្ធតែជាអ្នកមិនដឹង មិនឃើញ តាមសភាវៈធម៌ដែលពិតទេ តែងសោយនូវអារម្មណ៍ក្នុងទិដ្ឋិនោះ ៗ តណ្ហា, ឧបាទាន, ភព, ជាតិ, ជរា, មរណៈ, សេចក្ដីសោកស្រណោះ, សេចក្ដីខ្សឹកខ្សួល សេចក្ដីមិនស្រួលកាយ, សេចក្ដីតូចចិត្ត, សេចក្ដីចង្អៀតចិត្ត, របស់ពួកសមណ-ព្រាហ្មណ៍នោះឯង តែងកើតមានឡើង ។ ពួកសមណព្រាហ្មណ៍ទាំងនោះដែលគ្រឿក ៦២ នេះឯងគ្របសង្កត់ហើយ រមែងធ្វើឲ្យដូចជានៅក្នុងសំណាញ់ អាស្រ័យនៅក្នុងសំណាញ់ កាលងើបឡើងក៏ងើបឡើងក្នុងសំណាញ់ ជាប់នៅក្នុងសំណាញ់ ប្រៀបដូចជាអ្នកនេសាទមច្ឆាជាតិក្ដី អ្នកជំនួយរបស់អ្នកនេសាទមច្ឆាជាតិក្ដី ដែលមិនប្រសប់បង់សំណាញ់ក្នុងអន្លង់ទឹកតូច ដោយគិតថាអញធ្វើសត្វតូចសត្វធំក្នុងអន្លង់ទឹកនេះ ឲ្យនៅក្នុងសំណាញ់ អាស្រ័យនៅក្នុងសំណាញ់ កាលងើបឡើងក៏ងើបឡើងក្នុងសំណាញ់ដូច្នោះឯង ។

ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះយ៉ាងនេះថា ហេតុនៃទិដ្ឋិទាំងឡាយនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ មានគតិយ៉ាងនេះ មានការប្រព្រឹត្តទៅក្នុងខាងមុខ

យ៉ាងនេះ ៗ តថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះផង ដឹងច្បាស់នូវសីល សមាធិ និងសព្វញ្ញុតញ្ញាណ ដែលជាគុណជាតលើសលុបក្រៃលែង ជាងនោះទៅទៀតផង, កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ មួយទៀត កាលបើតថាគត មិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅ នៃបកាសពិសេស ដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវគុណនៃវេទនាផង នូវទោសនៃវេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ៗ ម្នាលភិក្ខុទាំងឡាយ តថាគតផុតស្រឡះហើយចាកកិលេស ព្រោះមិនបានប្រកាន់នូវធម៌ណាមួយមានខន្ធជាដើម ។ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសំដែងនូវធម៌ទាំងឡាយឯណា, ពួកជនកាលពោលសរសើរគុណរបស់តថាគតតាមសេចក្តីពិតដោយធម៌ទាំងឡាយឯណា, ធម៌ទាំងឡាយនេះឯងហើយ ដែលជាធម៌ដ៏ជ្រាលជ្រៅ ដែលបុគ្គលកម្រឃើញបាន ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។

ចប់ ទិដ្ឋិ ៦២ ប្រការ ។

## អន្តគ្គាហិកទិដ្ឋិ

មិច្ឆាទិដ្ឋិប្រកាន់យកហេតុជាទីបំផុត ហៅថា អន្តគ្គាហិកទិដ្ឋិ(១) មានវត្ថុ ១០ យ៉ាងគឺ:

១- សស្សតោ លោកោ [ប្រកាន់ថាលោកទៀង]

២- អសស្សតោ លោកោ [ប្រកាន់ថាលោកមិនទៀង]

៣- អន្តវា លោកោ [ប្រកាន់ថាលោកមានទីបំផុត

៤- អនន្តវា លោកោ [ប្រកាន់ថាលោកមិនមានទីបំផុត

៥- តំ ជីវំ តំ សរីរំ [ប្រកាន់ថាជីវៈនោះគឺសរីរៈនោះ

៦- អញ្ញំ ជីវំ អញ្ញំ សរីរំ [ប្រកាន់ថាជីវៈដទៃ សរីរៈក៏ដទៃ

៧- ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វកើតទៀត] ខាងមុខអំពីសេចក្តីស្លាប់

៨- ន ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វមិនកើតទៀត] ខាងមុខអំពីសេចក្តីស្លាប់

៩- ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វកើតទៀត]ក៏មាន មិនកើតទៀត]ក៏មាន ខាងមុខអំពីសេចក្តីស្លាប់

---

១ ទិដ្ឋិនេះ ឃាត់តែមគ្គ មិនឃាត់សួគ៌ទេ ព្រោះការយល់ខុសបែបនេះ មិនទាន់ធ្លាក់ក្នុងកម្មបថនៃកម្ម ។

៩០- នេវ ហោតិ ច ន ហោតិ តថាគតោ បរម្មរណា [ប្រកាន់ថាសត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ។

## សក្កាយទិដ្ឋិ

សេចក្តីយល់ឃើញដែលជាហេតុឲ្យប្រកាន់ខ្លួន ហៅថា សក្កាយទិដ្ឋិ[១] មាន ២០ យ៉ាងគឺ

### ពួករូបក្ខន្ធ

១- រូបំ អត្តតោ សមនុបស្សតិ ពិចារណាឃើញរូបថាជាខ្លួន

២- រូបវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានរូប

៣- អត្តនិ រូបំ សមនុបស្សតិ ពិចារណាឃើញរូបក្នុងខ្លួន

៤- រូបស្មឹ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងរូប

### ពួកវេទនាខន្ធ

៥- វេទនំ អត្តតោ សមនុបស្សតិ ពិចារណាឃើញវេទនាថាជាខ្លួន

៦- វេទនាវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានវេទនា

---

១ ទិដ្ឋិនេះឃាត់តែមគ្គមិនឃាត់សួគ៌ ដូចគ្នានឹងអត្តានុទិដ្ឋិដែរ ។

៧- អត្តនិ វេទនំ សមនុបស្សតិ ពិចារណាឃើញវេទនាក្នុងខ្លួន

៨- វេទនាយ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងវេទនា

## ពួកសញ្ញាខន្ធ

៩- សញ្ញំ អត្តតោ សមនុបស្សតិ ពិចារណាឃើញសញ្ញាថាជាខ្លួន

១០- សញ្ញាវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានសញ្ញា

១១- អត្តនិ សញ្ញំ សមនុបស្សតិ ពិចារណាឃើញសញ្ញាក្នុងខ្លួន

១២- សញ្ញាយ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងសញ្ញា

## ពួកសង្ខារក្ខន្ធ

១៣- សង្ខារេ អត្តតោ សមនុបស្សតិ ពិចារណាឃើញសង្ខារទាំងឡាយថាជាខ្លួន

១៤- សង្ខារវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានសង្ខារ

១៥- អត្តនិ សង្ខារេ សមនុបស្សតិ ពិចារណាឃើញសង្ខារទាំងឡាយក្នុងខ្លួន

១៦- សង្ខារេសុ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងសង្ខារទាំងឡាយ

## ពួកវិញ្ញាណក្ខន្ធ

១៧- វិញ្ញាណំ អត្តតោ សមនុបស្សតិ ពិចារណាឃើញវិញ្ញាណជាខ្លួន

១៨- វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនថាមានវិញ្ញាណ

១៩- អត្តនិ វិញ្ញាណំ សមនុបស្សតិ ពិចារណាឃើញវិញ្ញាណក្នុងខ្លួន

២០- វិញ្ញាណស្មិំ អត្តានំ សមនុបស្សតិ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណ ។

## ទោសមិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិមានទោសយ៉ាងណាខ្លះ ចូរអធិប្បាយមកមើល?

វត្ថុទាំងឡាយដែលមានទម្ងន់ ដូចយ៉ាងថ្មក្រួស ដុំដីជាដើម សូម្បីមានទំហំប្រមាណប៉ុនគ្រាប់សណ្តែកបាយ ឬ សណ្តែកផាស

ដែលបុគ្គលបោចបោះចោលទៅក្នុងទឹក, ជ្រោះ ឬ ស្រះជាដើមនោះមិនអាចនឹងកណ្ដុះបានទៀយ មានតែធ្លាក់លិចចុះទៅក្នុងទឹកសស្រើម ត្រាតែដល់តែនដីទើបឈប់, មួយទៀត លាមកវត្ថុដែលមានក្លិនស្អុយ កុំថាច្រើនសម្បូរយ៉ាងតិចបំផុត ក៏គង់មានក្លិនអសោចដែលគួរឲ្យខ្ពើមរអើមមិនខាន សេចក្ដីនេះមានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចមិច្ឆាទិដ្ឋិទាំងឡាយដែលបានពោលមកខាងដើមនោះសុទ្ធតែជាធម៌នាំបណ្ដាលឲ្យមានទោសដល់ពួកសត្វទាំងនាំសត្វឲ្យទៅកើតក្នុងអបាយទាំង ៤ មាននរកជាដើមដូច្នោះឯង ។ ហេតុនោះ ជនជាបណ្ឌិតកុំគប្បីប្រកាន់ថា មិច្ឆាទិដ្ឋិនុះមិនបាននាំសត្វឲ្យទៅកើតក្នុងអបាយដូច្នេះឡើយ, សមដូចព្រះពុទ្ធត្រាស់ក្នុងគម្ពីរឯកនិបាតអង្គុត្តរថា: នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ, យេនេវំ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ, យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ; មិច្ឆាទិដ្ឋិយា ភិក្ខវេ សមន្នាគតា សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ (សេចក្ដីថា) ម្នាលភិក្ខុទាំងឡាយ, តថាគតពិនិត្យមើលៈមិនឃើញមានធម៌ដទៃសូម្បីតែធម៌មួយដែល ជាធម៌នាំពួកសត្វដែលបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ឲ្យទៅកើតក្នុងអបាយ, ទុគ្គតិ, វិនិបាត, នរក ក្រៅអំពីមិច្ឆាទិដ្ឋិនេះឡើយ; ម្នាលភិក្ខុទាំងឡាយ, ពួកសត្វដែលប្រកបដោយមិច្ឆាទិដ្ឋិហើយ, លុះដល់បែក

ធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ ទើបតែទៅកើតក្នុងអបាយ, ទុគ្គតិ, វិនិបាត, នរក (ជាប្រាកដ) ។

ហេតុនោះ សាធុជនដែលមានប្រាជ្ញាល្អ ជាអ្នកប្រាថ្នាសេចក្ដីសុខ សេចក្ដីចំរើន ប្រាថ្នាឲ្យរួចចាកទុក្ខទាំងពួង គួរតែប្រាប់អំពីទោសមិច្ឆាទិដ្ឋិនោះ ដោយសព្វគ្រប់; កាលៈបើប្រាជ្ញាច្បាស់ហើយ ត្រូវកុំធ្វើខ្លួនឲ្យជាមនុស្សមិច្ឆាទិដ្ឋិឡើយ ឬ ពួកជនណា ធ្លាប់ជាអ្នកមិច្ឆាទិដ្ឋិស្រាប់ហើយ ក៏គួរលះបង់មិច្ឆាទិដ្ឋិនោះចេញ ហើយសមាទានកាន់យកសម្មាទិដ្ឋិវិញ ទើបនឹងរួចចាកទុក្ខទាំងពួងផង ឈ្មោះថាជាអ្នកមិនមែនជាចំរូង ឬមិនមែនជាជន្លក់ក្នុងសាសនាផង; ព្រោះថា ព្រះពុទ្ធសាសនានៅមែត្តស្ពានក្នុងទីណា ទីនោះបើមានមនុស្សមិច្ឆាទិដ្ឋិច្រើន ព្រះពុទ្ធសាសនាមិនគាបនឹងប្រព្រឹត្តទៅបានដោយស្រួលទេ ។

ម្យ៉ាងទៀត មនុស្សមិច្ឆាទិដ្ឋិនេះរាប់ថាជាបុគ្គលអន្ធពាលដែលអ្នកប្រាជ្ញតែងតិះដៀលថាជា "មនុស្សទុស្សលោក" គឺគ្រាន់តែកើតមកជាមនុស្សឲ្យបង្អៀតក្នុងលោកមិនបានធ្វើលោកនេះឲ្យចំរើនរុងរឿងឡើយ ។ នឹងអធិប្បាយចំពោះពាក្យថា "មនុស្សទុស្សលោក" តទៅ:-

ត្រង់ពាក្យថា "លោក" ក្នុងទីនេះ បើពោលដោយព្យញ្ជនៈ បានដល់ទីនៅអាស្រ័យរបស់សត្វទាំងឡាយ, បើពោលដោយអត្ថ បានដល់ពួកសត្វដែលនៅលើផែនដី ។ ពាក្យថា "មនុស្សទុស្សលោក"

សំដៅយកមនុស្សដែលមានយោបល់យល់ខុស ប្រព្រឹត្តធ្វើតែសេចក្ដីអាក្រក់ដោយកាយ វាចា ចិត្ត ជាប្រក្រតីនោះឯង ៗ ឯលោកនឹងរុងរឿងថ្កុំសោភស្ងួននោះ រមែងបណ្ដាលមកអំពីពួកមនុស្សដោយច្រើនក្រៃលែងជាងរបស់ឯទៀត ព្រោះថាបើមនុស្សទាំងឡាយជាបណ្ឌិតមានសេចក្ដីយល់ឃើញត្រូវ តាំងនៅក្នុងសីលធម៌ មានហិរិ សេចក្ដីខ្មាស, ឱត្តប្ប សេចក្ដីក្រែងខ្លាចចំពោះបាបកម្ម គឺសេចក្ដីអាក្រក់ដែលជាប់ជិតស្អិតនៅក្នុងដួងចិត្តហើយ, រមែងមិនប្រាថ្នាដើម្បីកេរឿងបៀតបៀនគ្នា មិនមានសេចក្ដីវង្វៀងសង្ស័យដល់គ្នានឹងគ្នារៀងៗខ្លួន ប្រកបការចិញ្ចឹមជីវិតក៏ដោយផ្លូវសុចរិតយុត្តិធម៌ ព្រមទាំងធ្វើការទំនុកបំរុងដល់គ្នានឹងគ្នាក្នុងសោមវិបត្តិ ដូចត្រូវចោរភ័យ អគ្គិភ័យនឹងទុក្ខភ័យជាដើម; កាលបើពួកមនុស្សប្រព្រឹត្តដូច្នេះ លោកឈ្មោះថាមានសេចក្ដីរុងរឿង, ចំណែកសត្វដែលអាស្រ័យនៅក្នុងលោកនោះ ក៏បានសេចក្ដីសុខប្រាសចាកទុក្ខភ័យន្តរាយ ឧបទ្រពគ្រប់យ៉ាង ៗ បើពួកជនច្រើនតែជាមនុស្សពាលមានសេចក្ដីប្រកាន់ខុសថាជាត្រូវ ប្រព្រឹត្តសេចក្ដីអាក្រក់ដោយផ្លូវកាយ, វាចា, ចិត្ត, ប្រាថ្នាគិតធ្វើការអ្វី បំណងយកតែប្រយោជន៍ផ្ទាល់ខ្លួនម្យ៉ាង គ្រង់ប្រយោជន៍ដល់ជាតិនឹងសាសនាមិនគិតសោះ កាលបើយ៉ាងនេះ សត្វក្នុងលោករមែងបានទទួលសេចក្ដីក្ដៅក្រហាយវិនាសចិត្ត ម្ល៉ោះហើយលោកក៏មិនមានដំណើរជឿនលឿនទៅរកសេចក្ដីរុងរឿងជាមួនបាន មាន

តែអំប្បូរនេះមេបុះផាយលំដាប់ ព្រោះហេតុនោះបានជាបណ្ឌិតតិះដៀល ជនពាលដែលមានសេចក្ដីយល់ខុសថាជា "មនុស្សទ្រុស្តលោក" ។ មួយទៀតមនុស្សពាលជាមិច្ឆាទិដ្ឋិនេះ ប្រៀបដូចជាផ្លែព្រស្វាកដែលកើតមកគ្រាន់តែស្អុកស្អាញក្នុងទីកន្លែងប៉ុណ្ណោះ, ការដែលប្រៀបដូច្នេះ ក៏គ្រាន់តែជាពាក្យឧបមាទេ, បើតាមសេចក្ដីពិត ជនពាលនោះឯង រមែងស្អុកស្អាញក្រៃលែងជាងផ្លែព្រស្វាកឬក្រៃលែងជាងសត្វតិរច្ឆានទៅទៀត ព្រោះផ្លែព្រស្វាកទោះជាស្អុកស្អាញយ៉ាងណា ក៏គង់តែមិនបៀតបៀនមនុស្សក្នុងលោកឲ្យសាបសូន្យឡើយ, គង់មានប្រយោជន៍ គេយកទៅធ្វើជាថ្នាំសំលាប់ការពារសត្វមានពោរជាដើមបានខ្លះ, ចំណែកសត្វតិរច្ឆានពួកខ្លះ សូម្បីខ្លួនវាស្លាប់ហើយ គេមិនអាចប្រើប្រាស់វាបានក៏មែនហើយ តែស្បែកឆ្អឹងនិងស្នែងរបស់វា ក៏គង់គេយកទៅធ្វើជាគ្រឿងប្រដាប់សំរាប់ប្រើប្រាស់បានខ្លះ, ឯជនពាលនឹងយកទៅធ្វើដូច្នោះមិនបាន មានតែបណ្ដាលទុក្ខទោសក្ដៅក្រហាយដល់អ្នកដទៃ កើតមកគ្រាន់តែជាភ្លៃក្នុងលោកប៉ុណ្ណោះឯង ។

មួយវិញទៀត បុគ្គលពាលជាមិច្ឆាទិដ្ឋិនោះ មិនមែនគ្រាន់តែធ្វើលោកឲ្យដល់នូវសេចក្ដីសាបសូន្យ ឬខូចដូចជាបំរុងទឹងជំនឿក្នុងសាសនាប៉ុណ្ណោះទេ តែងធ្វើខ្លួនឯងឲ្យបានទទួលទុក្ខទោសក្នុងបច្ចុប្បន្នទាំងបរលោកថែមទៀតផង ។

ទោសមិច្ឆាទិដ្ឋិដូចសំដែងមកនេះ ជាបរិយាយដោយរួបរួមមិនបានញែកបញ្ចេញឲ្យឃើញផ្សេងៗ ពីគ្នាថា មិច្ឆាទិដ្ឋិណាមានទោសយ៉ាងណាៗ កំនៅឡើយទេ ។ អំពីនេះនឹងសំដែងអំពីទោសមិច្ឆាទិដ្ឋិ ឲ្យឃើញផ្សេងៗគ្នា តាមសេចក្ដីដែលព្រះសារីមង្គលាចារ្យលោកបានដកស្រង់ពីគម្ពីរផ្សេងៗ មករៀបរៀងទុកក្នុងគម្ពីរមង្គលត្ថទីបនីត្រង់នេះយកជាដូចមានបាឡីជាដើមថា: ឯកច្ចា មិច្ឆាទិដ្ឋិ សគ្គាវរណា ចេវ ហោតិ មគ្គាវរណា ច: ឯកច្ចា មគ្គាវរណាវ ន សគ្គាវរណា (សេចក្ដីថា) មិច្ឆាទិដ្ឋិពួកខ្លះ ឃាត់សួគ៌ផង ឃាត់មគ្គផង, ពួកខ្លះឃាត់តែមគ្គម្យ៉ាង មិនបានឃាត់សួគ៌ទេ ។

មិច្ឆាទិដ្ឋិពួកណា ឃាត់សួគ៌ផង ឃាត់មគ្គផង? មិច្ឆាទិដ្ឋិពួកណា ឃាត់តែមគ្គមិនឃាត់សួគ៌?

បណ្ដាមិច្ឆាទិដ្ឋិទាំងនោះ, អហេតុកទិដ្ឋិ អកិរិយទិដ្ឋិ និង នត្ថិកទិដ្ឋិ ទាំង ៣ នេះ ឃាត់សួគ៌ផង ឃាត់មគ្គផង គឺស្ទះទប់គតិរបស់សត្វមិនឲ្យទៅសោយសម្បត្តិសុខក្នុងស្ថានសួគ៌ ទាំងមិនឲ្យលុះមគ្គផលជាន់ខ្ពស់បានឡើយ; ឯ អនិយតមិច្ឆាទិដ្ឋិ និង និយតមិច្ឆាទិដ្ឋិទាំង ២ នេះ ក៏ឃាត់សួគ៌នឹងមគ្គដែរ, ប៉ុន្តែបើនិយាយអំពីទោសតូចនិងទោសធំ អនិយតមិច្ឆាទិដ្ឋិមានទោសតូច, និយតមិច្ឆាទិដ្ឋិមានទោសធំ ។ ពិតដូច្នោះមែន ព្រះសា-រីមង្គលាចារ្យ លោកក៏បានពោលថា: អនន្តរិយកម្មតោបិ និយតមិច្ឆាទិដ្ឋិ

មហាសាវជ្ជតរំ វេទិតព្វំ (សេចក្តីថា) លោកអ្នកប្រាជ្ញមានប្រាជ្ញាគួរប្រាប់ថា និយតមិច្ឆាទិដ្ឋិ មានទោសធំជាងអនន្តរិយកម្មទៅទៀត ។ បានជាពោលដូច្នោះ ព្រោះអាងព្រះពុទ្ធដីកាដែលសម្តេចព្រះឈ្នះមារជាម្ចាស់ត្រាស់ទុកក្នុងគម្ពីរឯកនិបាតអង្គុត្តរថា: នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំឯវំ មហាសាវជ្ជំ, យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ; មិច្ឆាទិដ្ឋិបរមានិ ភិក្ខវេ វជ្ជានិ (សេចក្តីថា) ម្នាលភិក្ខុទាំងឡាយ, តថាគតបានពិនិត្យរកមើលមិនឃើញមានធម៌ដទៃឯណា សូម្បីតែធម៌មួយដែលមានទោសធំ ឲ្យដូចជានិយតមិច្ឆាទិដ្ឋិនេះឡើយ; ម្នាលភិក្ខុទាំងឡាយ ទោស (ដែលធំ) បំផុត ស្រេចហើយត្រឹមនិយតមិច្ឆាទិដ្ឋិ ។

ព្រះពុទ្ធភាសិតដែលបានលើកមកសំដែងអាងនេះ គួរមានសេចក្តីសង្ស័យកើតឡើងដល់ពុទ្ធបរិស័ទ ដែលបានមើលឬបានស្តាប់ថា អនន្តរិយកម្ម ៥ យ៉ាងគឺ: មាតុឃាត = សម្លាប់មាតា ១ បិតុឃាត = សម្លាប់បិតា ១ អរហន្តឃាត = សម្លាប់ព្រះអរហន្ត ១ លោហិតុប្បាទ = ប្រទូស្តបំពោះព្រះសម្ពុទ្ធ ធ្វើឲ្យពុះពង់ចេញព្រះលោហិត ១ សង្ឃភេទ = បំបែកសង្ឃ ១ កម្មទាំង ៥ យ៉ាងនេះ ជាអំពើមានទោសធំ, ចុះនិយតមិច្ឆាទិដ្ឋិនុះឯង ដែលទ្រង់សំដែងថាមានទោសធំជាងអនន្តរិយកម្មទៅទៀត តើព្រោះហេតុដូចម្តេច?

នឹងវិសជ្ជនាប្រស្នានេះ តាមន័យដែលមានមកក្នុងអដ្ឋកថា និងដីកា នៃឯកនិបាតអង្គុត្តរនោះ ដូចមានសេចក្តីតទៅនេះ :

និយតមិច្ឆាទិដ្ឋិ បានជាព្រះអង្គសំដែងថាមានទោសធំជាងអនន្តរិយកម្ម ព្រោះអនន្តរិយកម្មនោះ ជាអំពើមានទោសកាចកំណត់ទីកំណត់ពេល ដែលសត្វទទួលនេះទុក្ខបាន, ចំណែកនិយតមិច្ឆាទិដ្ឋិមិនកំណត់ទីមិនកំណត់ពេលទេ, មែនពិតបណ្តាអនន្តរិយកម្ម ៥ នោះកម្ម ៤ យ៉ាងគឺមាតុឃាត, បិតុឃាត, អរហន្តឃាត និងលោហិតុប្បាទ សម្តេចព្រះជិនស្រីត្រាស់ថា ជាអំពើនាំសត្វឲ្យទៅកើតក្នុងនរកគឺមានកំណត់ តែមុខជាទីរួចចាកទុក្ខបាន, ចំណែកសង្ឃភេទកម្មញ៉ាំងសត្វឲ្យស្ថិតនៅក្នុងនរកអស់កំណត់ ១ កប្បប៉ុណ្ណោះ ៖ ឯនិយតមិច្ឆាទិដ្ឋិនោះ នឹងរកទីកំណត់ រកទីផុតរួចចាកទុក្ខឲ្យដូចជាអនន្តរិយកម្មមិនមានឡើយ ព្រោះនិយតមិច្ឆាទិដ្ឋិ លោកថាជាឫសគល់នៃសង្សារវដ្ត, ចំណែកសត្វដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិនេះ មិនអាចនឹងរួចចេញចាកកងវដ្តសង្សារ ទៅតាំងនៅក្នុងស្ថានព្រះនិព្វានបានទេ តែងអន្ទោលទៅមកយោនយកកំណើតកើតស្លាប់ក្នុងវាលវដ្តសង្សារនេះទុកលំបាករកកំណត់មិនបាន បើអ្នកណាចូលទៅសេពគប់នឹងបុគ្គលជានិយតមិច្ឆាទិដ្ឋិៗ នោះ នឹងដឹកនាំអ្នកនោះឯងឲ្យប្រតិបត្តិខុសផ្លូវដ៏ប្រពៃ គឺអដ្ឋង្គិកមគ្គ មួយទៀត បុគ្គលប្រកបដោយនិយតមិច្ឆាទិដ្ឋិ វៀរនឹងបានទៅកើតក្នុងស្ថានសួគ៌ វៀរនឹងបានលុះមគ្គផល កាលបើកប្ប

វិនាសដោយភ្លើងនេះ ពួកមហាជនទាំងគ្នាចំបើងឈាន ហើយបានទៅកើតក្នុងព្រហ្មលោកទាំងអស់គ្នា ចំណែកខាងបុគ្គលជានិយតមិច្ឆាទិដ្ឋិទៅកើតឯបិដ្ឋិចក្កវាឡ គឺចក្កវាឡខាងក្រោយពីចក្កវាឡដែលភ្លើងនេះប្រល័យកល្បកាលភ្លើងប្រល័យកល្បនេះរាលទៅដល់បិដ្ឋិចក្កវាឡនោះ សត្វជានិយតមិច្ឆាទិដ្ឋិអណ្តែតទៅនៅក្នុងអាកាសជាទីរាលមួយ ហើយនេះដោយអំណាចកំលាំងកម្មរបស់ខ្លួនឯង ។ និយតមិច្ឆាទិដ្ឋិមិនមានទីកំណត់ដែលទីនាំសត្វប្រចាំតទុក្ខដូចសំដែងមកនេះឯង ទើបព្រះលោកគ្រូមហាវេរជាម្ចាស់ត្រាស់ថា និយតមិច្ឆាទិដ្ឋិមានទោសធំបំផុត ។

សុនកាមបុគ្គល គួរគេចវៀះវៀសអំពីនូវបុគ្គលជាមិច្ឆាទិដ្ឋិឲ្យផុតស្រឡះចេញ ព្រោះជនពួកនេះរមែងធ្វើបុគ្គលដែលបានសេពគប់ប្រុលគំនិតផងនោះ ឲ្យមានសេចក្តីអន្តរាយជាច្រើនប្រការ ។ ហេតុនោះ បានជាអដ្ឋកថាចារ្យលោកសំដែងជាសេចក្តីក្រើនរំឭក ទុកក្នុងអដ្ឋកថានៃសាមញ្ញផលសូត្រថា :

តស្មា អកល្យាណជនំ អាសីវិសមិវោរគំ
អារកា បរិវជ្ជេយ្យ ភូតិកាមោ វិចក្ខណោ

អកល្យាណជនរមែងជាបច្ច័យនៃភាពជាដង្គត់ក្នុងសង្សារ ព្រោះហេតុនោះ អ្នកប្រាជ្ញមានប្រាជ្ញាជានូវសេចក្តីចំរើន (ដោយគុណមានសីល

ជាដើម) គប្បីគៀសកុំឲ្យក្លាយខ្លួនអែកលោភពេកដល់នោះ ជួបបុគ្គលជៀស

អន់កស់ដែលមានការសំពិសដូច្នោះឯង ។

មិត្តទុច្ចិកថា ការសំដែងអំពីមិត្តទុច្ចិ មិនបានពិស្ដារពេកណាស់

ណាទេ ក៏មុខតែជាចប់ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះ ។

# ព្រះគ្រូមហាបទុម ម៉ាយ-ស៊ុន រៀបរៀង

(តមក)

គឺគួរពោលតែកថា ដែលជាហេតុណែនាំជនអ្នកមិនទាន់ព្រមព្រៀងឲ្យព្រមព្រៀងគ្នាឡើង នាំជនអ្នកព្រមព្រៀងស្រាប់ហើយឲ្យរឹងរឹតតែជិតស្និទ្ធចំរើនឡើង ព្រោះសេចក្តីសាមគ្គីជាកិច្ចយ៉ាងសំខាន់ អាចញ៉ាំងប្រ-យោជន៍ទោះតិចច្រើនឲ្យសម្រេចបានដោយងាយ; ហេតុនេះគួរលះបង់សំដីញុះញង់សិកសៀត ហើយពោលតែកថាដែលជាហេតុញ៉ាំងសេចក្តីសាមគ្គីឲ្យកើតក្នុងសន្តាននោះទើបចាត់ជាគុណគួរប្រកបរឿយៗ ។

## ៥– មច្ឆេរវិនយេ យុត្តៈ

"សេចក្តីប្រកបខ្លួនក្នុងការនាំបង់នូវសេចក្តីកំណាញ់"

ខ នេះបានដល់ការបរិច្ចាគវត្ថុរបស់ខ្លួនឲ្យទៅជាទានដល់អ្នកដទៃ; ចេតនាដែលជាហេតុលោភឲ្យឈ្មោះថាទាន ។ ពោលដោយអាការមាន ២ គឺការឲ្យដើម្បីបូជាគុណ ដូចបុត្តធីតាជូនវត្ថុរបស់ខ្លួនចំពោះមាតាបិតាជាដើម ១ ការឲ្យដោយសេចក្តីសង្គ្រោះសម្រាប់អ្នកមានឋានៈខ្ពស់ គប្បីឲ្យដល់បុគ្គលតាមជាន់ខ្លួន ឬមានឋានៈស្មើគ្នា ១ ។ ទាននេះកាលបើញែកចេញទៅតាមចំណែកនៃការបរិច្ចាគ មានពីរប្រភេទ គឺសាធារណទាន ១ អសាធារណទាន ១; សាធារណទាន = ការឲ្យទៅមិនបានចំពោះរូប

បានដល់ការបរិច្ចាគទ្រព្យកសាងផ្លូវថ្នល់ស្ពាន ដែលជាទីសម្រាប់បំពេញព្រហ្មវិហារធម៌ នឹងជាទីសម្រាប់បំពេញបុណ្យកុសលរបស់ជនទូទៅ ឬការបំណាយធនធានសាងរោងព្យាបាល ដែលជាទីបំបាត់រោគាព្យាធិរបស់ពួកជនផ្សេងៗ សាងរោងរៀនវិជ្ជាវិទ្យាសម្រាប់កុលបុត្រ នឹងការសាងស្ពានសង់សាលាសំណាក់ លើកថ្នល់ ជីកអណ្តូងទឹកដែលជាការឲ្យសេចក្តីសុខដល់ជនទូទៅមិនចំពោះមុខ ទាំងអស់នេះ ចាត់ជាសាធារណទានចំណែកមួយ ៗ

ម្យ៉ាងទៀត ការសាងសៀវភៅគម្ពីរក្បួនខ្នាតផ្សេងៗ ឬសំដែងពាក្យប្រដៅក្នុងផ្លូវព្រះពុទ្ធសាសនា ដែលជាសេចក្តីប្រតិបត្តិដឹកនាំឲ្យតាំងនៅក្នុងសេចក្តីល្អ ចែកដល់ពួកជនទូទៅ ក៏ចាត់ជាសាធារណទានដូចគ្នាដែរ ៗ

ឯអសាធារណទាននោះ គឺការឲ្យដោយចំពោះ ដូចការឲ្យដើម្បីបូជាគុណដល់ពុទ្ធការីបុគ្គល មានមាតាបិតានឹងគ្រូឧបជ្ឈាយាចារ្យជាដើម ឬឲ្យដល់បុគ្គលអ្នកទីទាល់ក្រីក្រលំបាកខ្សត់ខ្សោយទ្រព្យសម្បត្តិ ឲ្យបានទទួលសេចក្តីសុខស្រួលបាន ឬឲ្យដល់បុគ្គលអ្នកទុព្វលភាពដែលខ្វះគ្រឿងចិញ្ចឹមជីវិត; ការដែលឲ្យចំពោះរូបដូច្នេះ ចាត់ជាអសាធារណទាន ៗ ការឲ្យនេះ ត្រូវអាស្រ័យទឹកចិត្តរបស់អ្នកបរិច្ចាគដែលថា ឲ្យគ្រឿងឧបភោគនឹងគ្រឿងបរិភោគ ដែលជារបស់គាប់ប្រយោជន៍ឲ្យសម្រេច

ដល់អ្នកទទួល មិនមែនសំដៅការបរិច្ចាគវត្ថុដែលឲ្យទោសដល់អ្នកទទួល មានឲ្យទឹកស្រវឹងជាដើមឡើយ ។ ប្រការមួយទៀត មិនមែនសំដៅយកការបរិច្ចាគ ដើម្បីបំពេញសេចក្ដីលោភដែលខុសសេចក្ដីប្រាថ្នារបស់ការបរិច្ចាគទាន ព្រោះការបរិច្ចាគទានដើម្បីបន្ទោបង់នូវសេចក្ដីកំណាញ់តែប៉ុណ្ណោះមិនមែនបំពេញសេចក្ដីលោភឲ្យចំរើនឡើង ដូចការបរិច្ចាគដោយប្រាថ្នាយកកម្រៃផលអំពីអ្នកទទួល គឺយកទ្រព្យទៅផ្ញើទុកក្នុងធនាគារដើម្បីដកយកកម្រៃដូច្នោះឡើយ ព្រោះការឲ្យបែបនោះឈ្មោះថាមិនបានប្រព្រឹត្តទៅដោយសេចក្ដីស្មោះដោយពិត ឬ បរិច្ចាគដោយសេចក្ដីប្រាថ្នាចង់មានទ្រព្យសម្បត្តិក្នុងជាតិមុខ ដោយមានជម្រើះថា ជាតិនេះខ្លួនជាអ្នកខ្សត់ខ្សោយសម្បត្តិហើយក៏បរិច្ចាគទៅ, ការបរិច្ចាគដូចពោលមកនេះរមែងមិនប្រពៃ កាលបើពោលដល់ផលការបរិច្ចាគហើយ ក៏រមែងមាននៅជាធម្មតា តែមិនគួរបរិច្ចាគឲ្យជាការទំនុកបំរុងសេចក្ដីលោភ បើបរិច្ចាគដើម្បីកាត់ ឬ លះបង់នូវកិលេស គឺសេចក្ដីកំណាញ់នោះទើបជាការប្រពៃ ។ ការបរិច្ចាគទានដោយអាការដែលល្អទាំង ២ ប្រការដែលពោលហើយនេះ ទើបឈ្មោះថាជាទានដ៏ល្អ ហៅថាសប្បុរិស-ទាន ។ សម្ពុទ្ធគាថាក៏មានត្រាស់ទុកថា វិចេយ្យ ទានំ សុគតប្បសត្ថំ ការពិចារណាមុនសិនហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរ ដូច្នេះឯង, សេចក្ដីនេះសំដែងឲ្យឃើញថាការបរិច្ចាគនោះ

ក៏ត្រូវតែជ្រើសរើសបុគ្គលនិងស្ថានដែលគួរឲ្យ ៗ ទានជាគុណជាតិ
មានប្រយោជន៍ក្នុងការទាញចិត្តអ្នកដទៃឲ្យស្រឡាញ់រាប់អានជាដើម
ហេតុនេះសាធុជនគួរប្រកបឲ្យកើតឡើងរឿយ ៗ សូម្បីព្រះពុទ្ធសាសនា
ដែលបានឋិតនៅហូតមកដល់សព្វថ្ងៃនេះ ក៏អាស្រ័យទានគឺការបរិច្ចាគ
របស់អ្នកមានសទ្ធា ទើបបានជាកំឡាំងជួយឧបត្ថម្ភដល់ជនទូទៅ បើ
ពោលដោយសេចក្តីពិតគឺផលនៃការបរិច្ចាគនេះ រមែងបញ្ចេញផលឲ្យ
ឃើញបានទាំងបំណែកខាងក្នុងនិងខាងក្រៅ គឺការបានពិចារណាហើយ
ទើបឲ្យ ចិត្តក៏រមែងកើតសេចក្តីជ្រះថ្លាក្នុងការបរិច្ចាគ ព្រោះ
ខ្លួនឯងបានស្វែងរកទ្រព្យសម្បត្តិមកដើម្បីទំនុកបំរុងខ្លួនឲ្យបានទទួលសុខ
ក្នុងបច្ចុប្បន្នព្រមទាំងបានចែកទ្រព្យសម្បត្តិរបស់ខ្លួន នោះឲ្យដល់ជនដទៃ
ដើម្បីប្រយោជន៍សេចក្តីសុខទៀត យ៉ាងនេះឈ្មោះថាបានបំពេញប្រយោជន៍
ទាំង ២ គឺអត្តត្ថៈ ប្រយោជន៍ខ្លួន បរត្ថៈ ប្រយោជន៍អ្នកដទៃ ៗ ព្រោះ
ហេតុនោះ ការបរិច្ចាគតែរបស់ខ្លួនឲ្យជាប្រយោជន៍ដល់អ្នកដទៃ រមែង
ជាផ្លូវកំចាត់ចោលនូវមន្ទិល គឺសេចក្តីកំណាញ់របស់ខ្លួនចេញបាន ទើប
ជាកុសលដែលសាធុជនគួរប្រកបឲ្យមានក្នុងសន្តាន ។

# សច្ចវាចា

"ពាក្យសច្ច ឬ សំដីពិត"

សេចក្តីជាសំដីពិតនេះ ជាគុណជាតិប្រសើរបរិសុទ្ធប្រាសចាក សេចក្តីសៅហ្មង ដូចនៃមណីដែលមានពន្លឺស្អាត គាបញ្ញាំងប្រយោជន៍ ខ្លួននឹងប្រយោជន៍លោកឲ្យសម្រេចបាន ជាហេតុនៃសេចក្តីទុកចិត្តរបស់ អ្នកដទៃនឹងធ្វើសេចក្តីរីករាយឲ្យកើតដល់ខ្លួន ។ បុគ្គលឯណាមិនពោលនូវ ពាក្យសច្ច រមែងធ្វើខ្លួនឲ្យបានទទួលផលគឺសេចក្តីវិនាស ព្រោះវាចា ដែលមិនប្រកបដោយសច្ចៈ រមែងជាហេតុនាំឲ្យកើតទោសចំពោះខ្លួន នឹងនាំឲ្យខានចិត្តរបស់ពួកជនដែលបានស្តាប់ សូម្បីលាភសក្ការៈដែល បម្រុងនឹងកើតឡើងក៏ត្រឡប់ជាខានបាន ទាំងលាភសក្ការៈដែលកើតមាន ស្រាប់ហើយក៏រមែងសាបសូន្យ, រួមសេចក្តីឲ្យឃើញបានដោយងាយ មក ក៏គឺជាហេតុនាំឲ្យវិនាសចាកសម្បត្តិទាំង ៣ គឺ និព្វានសម្បត្តិ ១ ទេវសម្បត្តិ ១ មនុស្សសម្បត្តិ ១ ព្រោះពាក្យមិនប្រកបដោយសច្ចៈនោះ ជាវាចារបស់ពួកជនពាលប្រកាន់កាន ។

ការពោលពាក្យពិតជាអំណោយប្រយោជន៍យ៉ាងសំខាន់ តែសេចក្តី ពិតនោះសំគាល់យកត្រង់សេចក្តីពិតក្នុងរឿងដែលប្រពៃ សមតាមពុទ្ធ- ភាសិតថា សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា

សេចក្តីថា "សប្បុរសទាំងឡាយតាំងសីចហើយ ក្នុងសច្ចៈដែលជាអត្ថនិងធម៌" ។ ហេតុនេះគប្បីឃើញតួយ៉ាង សច្ចដែលប្រកបដោយអត្ថនិងធម៌ ដូចពាក្យរបស់ឧបតិស្សបរិព្វាជក និងកោលិតបរិព្វាជក ដែលធ្វើកតិកាប្តេជ្ញាដល់គ្នានិងគ្នាថា យើងទាំងពីរនាក់ដែលដើរទៅស្វែងរកមោក្ខធម៌នេះ បើអ្នកណាបានសម្រេចធម៌មុន អ្នកនោះត្រូវត្រឡប់មកប្រាប់ដល់គ្នានិងគ្នា ដូច្នេះ; ចំណែកខាងឧបតិស្សបរិព្វាជកបានស្តាប់ធម៌ទេសនារបស់ព្រះអស្សជិត្ថេរបានលុះអមតធម៌មុន ក៏បានទៅសំដែងប្រាប់ដល់កោលិតបរិព្វាជកជាសម្លាញ់តាមសេចក្តីប្តេជ្ញា កោលិតបរិព្វាជកក៏បានលុះធម៌ដូចគ្នា, នេះឯងគឺសេចក្តីពិតដែលជាអត្ថនិងដែលជាធម៌ ។ ម្យ៉ាងទៀត ពាក្យសច្ចដែលជាប្រយោជន៍ខ្លួននិងជាប្រយោជន៍លោកឈ្មោះថាប្រកបដោយអត្ថ ។ គុណគឺសេចក្តីល្អឈ្មោះថាជាធម៌, ការពោលពាក្យសច្ចៈដែលប្រកបដោយអត្ថនិងធម៌នេះ សាធុជនប្រុសស្រីគួរចំរើនបណ្តុះបណ្តាលឲ្យកើតឡើងក្នុងសន្តាន គឺកាលបើសច្ចៈធម៌ដែលមិនទាន់មាន គួរធ្វើឲ្យកើតមានឡើង បើកើតមានស្រាប់ហើយគួរចំរើនប្រែងរក្សាកុំឲ្យសាបសូន្យខាតខូចទៅឡើយ ព្រោះសេចក្តីពិតត្រង់នេះ ជាធម្មជាតគួរជាទីប្រាថ្នារបស់ពួកសប្បុរសទាំងពួង សូម្បីព្រះដ៏មានព្រះភាគក៏ទ្រង់ត្រាស់សរសើរទុកថា សច្ចំ វេ អមតា វាចា "វាចាពិតជាពាក្យមិនស្លាប់ គឺជាពាក្យញ៉ាំងប្រយោជន៍ឲ្យសម្រេច" ។

(មានត)